PROPHETIC
REVELATION

# អ្នក
# មិនអាច
# ថ្វាយអ្វីដល់ព្រះ ស្មើនឹងអ្វី
# ដែលព្រះប្រទានមកអ្នកទេ

ការ
បង្រៀន
ព្រះគម្ពីរ អំពី
ដង្វាយ១ភាគ១០ និង
ដង្វាយស្ម័គ្រចិត្ត

អ្នកណាដែលមានត្រចៀក ឱ្យអ្នកនោះស្ដាប់ចុះ!

# បុព្វកថា

ការអនុវត្តការដាក់ដង្វាយស្មគ្រពីចិត្ត នឹងដង្វាយ១ភាគ១០ តែងតែជារឿង**ចំរូងចំរះរវាង**អ្នកជឿជាក្រុមជំនុំ នឹងអ្នកធ្វើព័ន្ធកិច្ច (អ្នកបំរើព្រះ)។ ប៉ុន្តែចំពោះ **ពូជពីសតាំងរបស់ព្រះវិញ** មិនមែនរឿងបែបនេះទេ។

តាំងពីការចាប់ផ្តើមនៃពេលវេលាមក ព្រះមានផែនការ អោយរាស្រ្តរបស់ទ្រង់ **ថ្វាយដង្វាយល្អបំផុត**ដល់ទ្រង់-**គឺពីផលដំបូងរបស់ពួកគេ។** មានមនុស្សភាគច្រើន មិនបានដឹងថា ពាក្យ "**ដង្វាយ១ភាគ១០**" មានន័យយ៉ាងម៉េចផង ដង្វាយ១ភាគ១០ "មានន័យថា" "១ភាគ១០" ឬ ១០%នៃកំនើន ឬចំណូលរបស់អ្នកណាម្នាក់។ នៅក្នុងទិសដៅនៃសៀវភៅនេះនឹងនិយាយអំពីការដាក់ដង្វាយ១ភាគ១០ ជាចំណែក១ភាគក្នុង១០ ពីអ្វីដែលត្រូវឧទ្ទិសនឹងថ្វាយដល់ព្រះ។

នៅក្នុងបទគម្ពីរបរិសុទ្ធ៦៦កណ្ឌ មាន៣៤ និយាយពីរបៀប១ឬផ្សេងទៀតជាមួយនឹងប្រធានបទនៃការអោយ (ថ្វាយ) នឹងការទទួល។ មានខយោង៧២និយាយពីការថ្វាយមានខយោង៤៨បង្ហាញពីសេចក្តីសន្យាដ៏មិនចេះខុសរបស់ព្រះអំពីព្រះពរដ៏បរិបូរចំពោះអ្នកដែលថ្វាយ-*"ចូរអោយទៅគេនោះនឹងបានអោយមកអ្នកដែរ គេនឹងវាល់អោយអ្នកយ៉ាងល្អទាំងញាត់ទាំងរលាក់ ហើយដាក់អោយហៀរនឹងយកមកដាក់បំពេញចិត្តអ្នកផង ដ្បិតគេនឹងវាល់អោយអ្នកតាមរង្វាល់ណាដែលអ្នកវាល់អោយគេ"(លូកា ៦:៣៨)*។

តើអ្នកណាអាចចោទប្រកាន់ព្រះ ថាទ្រង់មិនរក្សាព្រះបន្ទូលសន្យាឬទេ? យើងជឿថាទ្រង់រក្សាសេចក្តីសន្យារបស់ទ្រង់លើសទៅទៀត។ យើងក៏ជឿលើការថ្វាយតាមសមាមាត្រហើយថាចំណូលអប្បបរមា ដែលត្រូវថ្វាយគឺ *"១ក្នុង១០"* ពីរបស់ដែលគេរកបានឬចំនូលរបស់គេឬប្រើពាក្យក្នុងគម្ពីគឺ *"ដង្វាយ១ក្នុង១០"*។ គ្មាននរណា១ពិតជាបានថ្វាយដល់ព្រះឡើយ ទាល់តែពួកគេថ្វាយដង្វាយ១ភាគ១០ជាមុនសិន។ យើងជឿថាមានគ្រិស្ទានជាច្រើនបានរងគ្រោះដោយសម្ភារៈ ខាងរូបកាយនឹងខាងវិញ្ញាណ ព្រោះពួកគេបានយកអ្វីដែលត្រូវថ្វាយព្រះ មកធ្វើជារបស់ខ្លួន។ យើងទុកចិត្តថាអ្នកមិនធ្វើដូចជាគេទេ ។

ក្នុងកំឡុងឆ្នាំ ១៩១៣-១៤ មានសំនួរ១ត្រូវបានគេបោះពុម្ពផ្សាយនៅក្នុងសារពត៌មាន១ចំនួនអំពីសាសនា នៅសហរដ្ឋអាមេរិច និងកាណាដាថា *"តើអ្នកបានស្គាល់អ្នកណាម្នាក់ ដែលមិនសប្បាយ មិនសប្បុរស ឬ ពុំសូវមានលុយកាក់ ដោយព្រោះគាត់ ជាអ្នកថ្វាយដង្វាយ១ភាគ១០ ឬទេ?"* គេបានទទួលចម្លើយ "ទេ" ១០០០០នាក់ ប៉ុន្តែចំលើយ "បាទ" គ្មានម្នាក់សោះ។

ទំនាយ ដែលបានបើកសំដែង

នៅក្នុងសៀវភៅនេះ យើងនឹងពន្យល់អំពីព្រះហឫទ័យដ៏គ្រប់លក្ខណ៍របស់ព្រះ តាមព្រះគម្ពីរដ៏ពិសិដ្ឋ ទាក់ទងទៅនឹងការថ្វាយដង្វាយ១ភាគ១០ និងរបៀបថ្វាយ និងគួរថ្វាយដោយរាស្រ្តរបស់ទ្រង់ ។

យើងសូមអធិស្ឋានថា សៀវភៅនេះនឹងជាព្រះពរដល់អ្នកឥឡូវនេះនិងថ្ងៃដែលត្រូវមកទៀត នៅពេលដែលអ្នកយកគោលការណ៍ គ្រឹះនៃការថ្វាយដង្វាយ១ភាគ១០នេះមកអនុវត្តនៅក្នុងជីវិតគ្រីស្ទានរបស់អ្នក ។

បំរើ
ជូន
ពួជរើសតាំងរបស់ព្រះ




---

សៀវភៅនេះគេត្រូវបានចងក្រងនិងកែសម្រួលពីប្រភពជាច្រើន។
សូមអរគុណ ជាពិសេសដល់ បងប្រុស Albert K.S. Ong សម្រាប់ការងារ វិចារណកថារបស់លោកលើការបោះពុម្ពផ្សាយដែលបានកែសំរួលនេះ។

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

## ហេតុអ្វី ត្រូវថ្វាយដង្វាយ១ភាគ១០?

**មានមូលហេតុ១២សំរាប់ការថ្វាយដង្វាយ១ភាគក្នុង១០**

១. ការថ្វាយដង្វាយ១ភាគក្នុង១០ មាននៅក្នុងបទគម្ពី ដែលព្រះបានអនុម័ត និង បង្គាប់ឲ្យធ្វើនៅក្នុងសញ្ញាចាស់និងសញ្ញាថ្មី ។

២. ការថ្វាយដង្វាយ១ភាគក្នុង១០ បង្រៀនឲ្យអ្នកថ្វាយបង្គំព្រះអម្ចាស់យេស៊ូគ្រីសដោយ ពិតត្រង់ ដាក់ព្រះនិងកិច្ចការរបស់ទ្រង់ជាមុនដំបូង។

៣. ការថ្វាយដង្វាយ១ភាគក្នុង១០ បង្រៀនអោយយើង ចំណាំ និងដឹងគុណព្រះដែលជា ម្ចាស់ជីវិតរបស់យើង ។

៤. ការថ្វាយដង្វាយ១ភាគក្នុង១០ គឺការថ្វាយបង្គំ ។

៥. ការថ្វាយដង្វាយ១ភាគក្នុង១០ធ្វើអោយយើងមានទំនុកចិត្តក្នុងការអធិស្ឋានទៅព្រះ ថែមទៀត។

៦. ការថ្វាយដង្វាយ១ភាគក្នុង១០ជាការអំពាវនាវឲ្យព្រះពររបស់ព្រះធ្លាក់មកលើអ្នកដែលថ្វាយ-ដង្វាយ១ភាគ១០។

៧. ការថ្វាយដង្វាយ១ភាគក្នុង១០ ទោរទន់ទៅរកការបង្កើតសមត្ថភាពរបស់អ្នកថ្វាយ-ដង្វាយ១ភាគ១០ឲ្យគេថ្វាយលើសពីដង្វាយ១ភាគ១០ពីរបស់ដែលគេរកបានទៅទៀត

៨. ការថ្វាយដង្វាយ១គាគ១០ផ្តល់ឳកាសដល់អ្នកថ្វាយ-ដង្វាយ១ភាគ១០បានទទួលព្រះពរពីព្រះចំពេលដែលពួកគេថ្វាយដង្វាយ១ភាគ១០ដល់ទ្រង់។

៩. ការថ្វាយដង្វាយ១ភាគ១០បង្កើតឲ្យមានតំណែងបញ្ញាជាមេអ្នកបំរើសនៅក្នុងជីវិតជាគ្រីស្ទានរបស់ពួកគេ។

១០.ការថ្វាយដង្វាយ១ភាគក្នុង១០ បង្កើតឥទ្ធិពលរបស់អ្នកថ្វាយ-ដង្វាយ១ភាគ១០ ទៅលើអ្នកដទៃទៀត ឲ្យដើរតាមគំរូរបស់គាត់ គឺថ្វាយដង្វាយ១ភាគ១០ដែរ ។

១១. ការថ្វាយដង្វាយ១ភាគក្នុង១០ គឺការថ្វាយតាមរបៀបជាប្រពន្ធ័ មិនមែនជាការថ្វាយតាមមនោសញ្ចេតនា ឬមិនទៀងទាត់នោះទេ ។

១២. ការថ្វាយដង្វាយ១ភាគក្នុង១០ បណ្តាលឲ្យអ្នកថ្វាយ-ដង្វាយ១ភាគក្នុង១០ថ្វាយដោយមានសេរីភាព និង ដោយស្មគ្រ័ពីចិត្តមិនមែនរង់ចាំទាល់តែគេអំពាវនាវឲ្យយើងថ្វាយនោះទេ ។

### ១ - ការថ្វាយដង្វាយ១ភាគក្នុង១០ នៅក្នុងសញ្ញាចាស់

**ការថ្វាយដង្វាយ១ភាគក្នុង ១០របស់កាអ៊ីន និងអេបិល**

ដើម្បីឲ្យយើងបានយល់អត្ថន័យ អំពីប្រធានបទណាទៀត ឲ្យបានច្បាស់លាស់យើងត្រូវចាប់ ផ្តើមសិក្សាអំពីប្រភពរបស់វាសិន-គឺអាល់ផា។ វាជារឿងជាក់ស្តែង ដែលការអ៊ីន បានទទួលការបង្រៀង ឲ្យអនុវត្តការថ្វាយដ

ង្វាយ១ភាគ១០ ពីឪពុកម្តាយរបស់គេគឺអ័ដាមនិងអេវ៉ា (សុភាសិត១:៨)ដែលពួកគាត់ក៏បានអនុវត្តរួចហើយផងដែរ។ ហើយគ្មាននរណាក្រៅពីព្រះទេដែលបង្រៀនអ័ដាម និងអេវ៉ាអំពីការថ្វាយដង្វាយ១ភាគ១០នេះ។

យើងអានពីរឿងរ៉ាវដំបូងនៃការអនុវត្តនេះ ក្នុងលោកប្បត្តិ ៤:២-៧ "*នាងក៏បង្កើតបានអេបិលជាប្អូនទៀត ឯអេបិលជាអ្នកគង្វាលហ្វូងសត្វ តែកាអ៊ីនជាអ្នកធ្វើស្រែចំការវិញ។ កន្លងក្រោយមកកាអ៊ីនបានយកផលដែលកើតពីដី មកថ្វាយជាដង្វាយដល់ព្រះយេហូវ៉ាហើយអេបិលក៏ធ្វើដូចគ្នា គឺគាត់យកកូនជាដំបូង១ពីហ្វូងសត្វមកថ្វាយ ព្រមទាំងខ្លាញ់របស់វាផង រួចព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យចំពោះអេបិលនិងដង្វាយរបស់គាត់ តែមិនសព្វព្រះហឫទ័យចំពោះដង្វាយរបស់កាអ៊ីនទេ នោះកាអ៊ីក៏ក្តៅក្រហាយ ហើយឡើងទឹកមុខក្រញូវ ព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរកាអ៊ីនថា ឯងខឹងធ្វើអី? ហេតុអ្វីបានជាឯងធ្វើទឹកមុខក្រញូវដូច្នេះ? បើឯងធ្វើល្អ តើមិនបានទឹកមុខរីករាយវិញទេវអី? បើឯងធ្វើមិនល្អនោះ មានដង្វាយដេកនៅមាត់ទ្វារស្រាប់ហើយ ចិត្តវានឹងបណ្តោយតាមឯង ហើយឯងមានអំណាចលើវាដែរ។*"

ចូរសំគាល់ពីដង្វាយខុសគ្នា ដែលបាននាំយកទៅថ្វាយព្រះ។ កាអ៊ីនបាននាំផលពីដី-មានបន្លែនឹងផ្លែឈើ។ អេបិលបាននាំយកកូនដំបូងពីហ្វូងសត្វព្រមទាំងខ្លាញ់វាផង។ ការថ្វាយយញ្ញបូជារបស់អេបិល គឺជាដង្វាយឈាមដែលចង្អុលទៅគំរូខុសគ្នានៃព្រះយេស៊ូគ្រីស្ទជារៀមច្បងនៃព្រះដែលជាដង្វាយសំរាប់លោះបាបជាច្រើន។

ចំណាំ អេបិលបាននាំយកកូនដំបូង ( ច្រើន )ពីហ្វូងចៀម នឹងសត្វផ្សេងទៀតដែលគាត់បានមើលថែ នោះបានគាប់ព្រះហឫទ័យព្រះ។ ព្រះបានប្រាប់អោយកាអ៊ីនទៅធ្វើអញ្ចឹងដែរដើម្បីអោយទ្រង់បានទទួលគាត់។ តើព្រះបានធ្វើតាម អ្វីដែលទ្រង់បានបង្គាប់មកឬទេ? ទេ តែគាត់បានចេញទៅរកប្អូនប្រុសរបស់គាត់ ហើយសំលាប់ប្អូនចោលវិញ។ ដូច្នេះ យើងអាចដឹងថា ពួកកូនដំបូង ដែលអេបិលបានថ្វាយទៅព្រះ គឺជាដង្វាយ១ភាគ១០ ហើយឈាមដែលបានខ្ចាយទៅលើអាសនា គឺជាសេចក្តីជំនឿរបស់គាត់ ចំពោះព្រះ ។

## ការថ្វាយដង្វាយ១ភាគ១០របស់អ័ប្រាហាំ

លោកុប្បត្តិ ១៤:១៧-២០ "*កាលគាត់បានត្រឡប់មកពីវាយកេដូឡោមើរនិងពួកស្តេចដែលនៅជាមួយពួកទ្រង់វិញហើយ នោះស្តេចក្រុងសូដុំមក៏ចេញមកទទួលគាត់ នៅត្រង់វាលច្រកភ្នំសាវេ គឺជាច្រកភ្នំនៃស្តេច ហើយមិ្ុលគីស្សាដែកជាស្តេចក្រុង សាឡិម ក៏នាំយកនំបុ័ងនិងស្រាទំពាំងបាយជូរមកពីព្រោះទ្រង់ជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុត ជាម្ចាស់នៃស្ថានសួគ៌ និងផែនដីហើយសូមព្រះដ៏ខ្ពស់បំផុតបានប្រកបដោយព្រះពរ ជាព្រះដែលបានប្រគល់*

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

*ខ្មាំងសត្រូវ មកក្នុងកណ្តាប់ដៃឯង រួចគាត់ក៏**ថ្វាយ ១ភាគក្នុង១០ ពីគ្រប់របស់ទាំងអស់ ដល់ទ្រង់**"។*

ការថ្វាយដង្វាយ១ភាគ១០របស់អ័ប្រាហាំដល់មិគិស្សាដែកនេះ ក៏បានចែក ឬក៏បន្ថែមនៅក្នុងហេព្រើរ ៧:២-១០ *"យលោកអ័ប្រាហាំបានយក**១ភាគក្នុង១០ ពីរបស់ទាំងអស់** ជូនលោក នាមស្តេចនោះ ដើមដំបូងស្រាយថា ស្តេចនៃសេចក្តីសុចរិត រួចមកជាស្តេចនៃក្រុងសាឡិម គឺថាជាស្តេចនៃសេចក្តីសុខសាន្ត លោកគ្មានមាតាបិតា គ្មានពង្សាវតាទេ ក៏គ្មានថ្ងៃកំណើតឬថ្ងៃស្លាប់ដែរ លោកមានភាពដូចជាព្រះរាជបុត្រានៃព្រះ ក៏នៅជាសង្ឃជាព្ធយុកោ **បានជូនរបឹប១ភាគក្នុង១០ផង** រីឯខាងឯពួកកូនចៅលេវី ដែលទទួលការងារជាសង្ឃ គេបានទទួលបង្គាប់តាមក្រឹតវិន័យ ឲ្យ**ហូតយក១ភាគ១០**ពីប្រជាជនដែរ គឺពីពួកបងប្អូនគេទាំងប៉ុន្មាន ទោះបើពួកនោះកើតពីពូជពង្សលោកអ័ប្រាហាំក៏ដោយ តែលោកម៉ិលគីស្សាដែកនេះដែលមិនបានរាប់ជាពង្សាគេទេ នោះបាន**ទទួល១ភាគក្នុង១០**ពីលោកអ័ប្រាហាំវិញ ហើយក៏អោយពរដល់លោកដែលបានទទួលសេចក្តីសន្យាទាំងប៉ុន្មានផងហើយច្បាប់នេះដែរថា គឺអ្នកធំអោយពរដល់អ្នកតូច នោះប្រកែកមិនបានឡើយ រីឯទីនោះ មនុស្សដែលតែងតែស្លាប់ **គេទទួល១ភាគក្នុង១០** នោះលោកឧបមាដូចជា បានថ្វា**យ១ភាគក្នុង១០** ដែរ ដោយសារលោកអ័ប្រាហាំ ដ្បិតលោកម៉ិលគីស្សាដែកបានទៅជួបនឹងលោកអ័ប្រាហាំ នោះលោកលេវីនៅជាពូជ ក្នុងខ្លួននៃព្ធយុកោលោកនៅឡើយ។"*

**លោកម៉ិលគីស្សាដែក** ជាគំរូនៃព្រះគ្រីស្ទ ជាសង្ឃ។ គាត់គ្មានមាតាបិតាទេ គ្មានកូនចៅ គ្មានថ្ងៃកំនើត និងគ្មានថ្ងៃស្លាប់ ប៉ុន្តែមានភាពដូចជាព្រះរាជបុត្រានៃព្រះ។ ឥឡូវនេះចូរចងចាំ សេចក្តីនេះ នៅក្នុងហេព្រើរ ១៣:៨ *"ព្រះយេស៊ូគ្រីស្ទទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ និងទៅដល់អស់កល្បជានិច្ចតទៅ។"* ដូច្នេះ តើអ្នកមិនដឹងថា នេះជាភារះកិច្ចរបស់ គ្រីស្ទានដែល **ត្រូវថ្វាយ (មិនមែនសងថ្លៃ)ដង្វាយ១ភាគ១០** នៅក្រោមសញ្ញាថ្មីនេះឬទេ?ចូរចងចាំផងដែលថា អ័ប្រាហាំ មិនមែនជាសាសន៍យូដាទេ មុននឹងឈ្មោះគាត់បានដូរនោះ។ សាសនាដាមិនទាន់មានទេ **រហូតទាល់តែពួកមេកុលសម្ព័ន្ធទាំង១២ បានកើតចេញមកពី**យ៉ាកុបសិន។

## ដង្វាយ១ភាគ១០របស់យ៉ាកុប

*"លោកយ៉ាកុបចាកចេញពីក្រុងបៀរសេបាឆ្ពោះទៅកាន់ស្រុកខារ៉ាន។ ពេលថ្ងៃជិតលិច លោកបានទៅដល់កន្លែងមួយ ហើយស្នាក់នៅទីនោះ។ លោកបានយកថ្មមួយដុំមកកើយ រួចសំរាន្តលក់នៅទីនោះទៅ។*

*លោកសុបិនឃើញមានជណ្ដើរមួយបញ្ឈរលើផែនដី ចុងវាខ្ពស់រហូតដល់មេឃ ហើយមានទេវតា*របស់ព្រះជាម្ចាស់ នាំគ្នាចុះឡើងតាមជណ្ដើរនោះ។*

*ពេលនោះ ព្រះអម្ចាស់គង់នៅក្បែរលោក មានព្រះបន្ទូលថា៖ យើងជាព្រះអម្ចាស់ ជាព្រះរបស់អប្រាហាំ ជីតាអ្នក ហើយក៏ជាព្រះរបស់អ៊ីសាកដែរ។ យើងនឹងប្រគល់ទឹកដីដែលអ្នកដេកលើនេះដល់អ្នក និងពូជពង្សរបស់អ្នក។*

*ពូជពង្សរបស់អ្នកនឹងមានចំនួនច្រើនដូចធូលីដី។ ទឹកដីរបស់អ្នកនឹងលាតសន្ធឹងទៅទិសខាងលិច ទិសខាងកើត ទិសខាងជើង និងទិសខាងត្បូង។ ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារអ្នក និងពូជពង្សរបស់អ្នក។*

*ចំពោះយើងផ្ទាល់ យើងនឹងស្ថិតនៅជាមួយអ្នក យើងនឹងថែរក្សាអ្នក គ្រប់ទីកន្លែងដែលអ្នកទៅ ហើយយើងនឹងនាំអ្នកត្រឡប់មកទឹកដីនេះវិញ ដ្បិតយើងមិនបោះបង់ចោលអ្នកឡើយ គឺយើងនឹងសំរេចអ្វីទាំងអស់តាមពាក្យដែលយើងសន្យានេះ។*
*លោកយ៉ាកុបភ្ញាក់ឡើង ហើយពោលថា៖ ព្រះអម្ចាស់ពិតជាគង់នៅកន្លែងនេះមែន តែខ្ញុំមិនដឹងសោះ!។*
*លោកភ័យខ្លាចជាខ្លាំង ហើយពោលថា កន្លែងនេះគួរអោយស្ញែងខ្លាចណាស់! គឺពិតជាព្រះដំណាក់របស់ព្រះជាម្ចាស់ ហើយពិតជាទ្វារនៃស្ថានបរមសុខ!។*
*លោកយ៉ាកុបក្រោកឡើងពីព្រលឹម យកដុំថ្មដែលលោកកើយនោះ មកដាក់បញ្ឈរជាស្តូប រួចចាក់ប្រេងពីលើ។*
*លោកដាក់ឈ្មោះកន្លែងនោះថាបេតអែល»។ ប៉ុន្តែ កាលពីដើម គេហៅកន្លែងនោះថា លូស។*
*លោកយ៉ាកុបបន់ថា ប្រសិនបើព្រះជាម្ចាស់គង់ជាមួយខ្ញុំ និងថែរក្សាខ្ញុំតាមផ្លូវដែលខ្ញុំធ្វើដំណើរទៅ ប្រសិនបើព្រះអង្គប្រទានអោយខ្ញុំមានអាហារបរិភោគ និងសម្លៀកបំពាក់*
*ហើយប្រសិនបើខ្ញុំវិលត្រឡប់ទៅផ្ទះឪពុកខ្ញុំវិញ ដោយសុខសាន្ត នោះខ្ញុំនឹងគោរពបំរើព្រះអម្ចាស់ទុកជាព្រះរបស់ខ្ញុំមែន។*
ដុំថ្មដែលខ្ញុំលើកបញ្ឈរឡើងនេះ ជាព្រះដំណាក់របស់ព្រះជាម្ចាស់! អ្វីៗដែល*ព្រះអង្គប្រទានមកទូលបង្គំ ទូលបង្គំនឹងយកមួយភាគដប់ថ្វាយព្រះអង្គវិញ"។*
(លោកុប្បត្តិ ២៨:១០-២២)

យ៉ាកុបបានស្គាល់យ៉ាងពិតប្រាដក ពីអ្វីដែលគាត់គួរធ្វើសំរេច បន្ទាប់ពីនិម្មិតនៃជណ្តើរនិងរបៀបថ្វាយដែលព្រះដ៏មានគ្រប់ព្រះចេស្តាសព្វព្រះហឫទ័យនៅទីនេះ គាត់បានសន្យាថា នឹង**ថ្វាយ១ភាគ១០-ដង្វាយ១ភាគ១០-**ពីអស់ទាំងរបស់ ដែលព្រះនឹងប្រទានដល់គាត់ទៅព្រះវិញ។ សូមគិតពីការនេះ គ្រប់

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

របស់ដែលយើងមាន គឺព្រះគុណនៃព្រះទេដែលបានប្រទានមកយើង នៅក្នុងកន្លែងទី១។ ដូច្នេះតើនេះមិនមែនមានអ្វី១ ដែលចូលមកក្នុងគំនិតរបស់យ៉ាកុបថា កិច្ចការទី១ គឺត្រូវថ្វាយ១ភាគ១០ទេឬអី។ ជាក់ស្តែង ឪពុករបស់គាត់ គឺអ៊ីសាក បានបង្រៀនគាត់អំពីការថ្វាយដង្វាយ១ភាគ១០។

**ការថ្វាយដង្វាយ១ភាគ១០ មិនមែនការសងថ្លៃដង្វាយ១ភាគ១០ទេ**

អ្នកបានសំគាល់ហើយថា មុននឹងក្រឹតវិន័យបានប្រទានមក ប្រជារាស្ត្ររបស់ព្រះ បានថ្វាយដង្វាយ១ភាគ១០ ដោយសេរីភាព មិនមែនសងថ្លៃដង្វាយ១ភាគ១០ទេ នៅពេលដែលក្រឹត្យវិន័យដែលត្រូវតែថ្វាយនោះ មិនទាន់បានប្រទានមកនៅឡើយ ។ ដូច្នេះការថ្វាយដង្វាយមិនគ្រាន់តែបានអនុវត្តនៅក្រោមក្រឹត្យវិន័យប៉ុណ្ណោះទេ ប៉ុន្តែបានអនុវត្តពីមុនក្រឹត្យវិន័យ (ច្បាប់) ទៀត។

**លេវីវិន័យ (ច្បាប់លេវី) អ៊ីស្រាអែល**

*"តង្វាយមួយភាគដប់ទាំងអស់គឺភោគផលដែលកើតចេញពីដី ឬផ្លែឈើក្តី ត្រូវទុកជាសក្ការៈថ្វាយព្រះអម្ចាស់។*

*ប្រសិនបើនរណាម្នាក់ចង់លោះតង្វាយមួយភាគដប់មកវិញ ត្រូវបង់ប្រាក់ចំនួនមួយភាគប្រាំថែមពីលើ។*

*ចំពោះហ្វូងគោ និងហ្វូងចៀម ក៏ត្រូវថ្វាយសត្វមួយភាគដប់ទុកជាសក្ការៈដល់ព្រះអម្ចាស់ដែរ។*

*ម្ចាស់មិនត្រូវរើសសត្វល្អ ឬមិនល្អ សំរាប់ថ្វាយព្រះអង្គទេ ហើយក៏មិនត្រូវយកសត្វផ្សេងមកដោះដូរសត្វដែលត្រូវថ្វាយនោះដែរ។ ប្រសិនបើគេយកសត្វមួយមកដូរយកសត្វមួយទៀត ត្រូវចាត់ទុកសត្វទាំងពីរជាសក្ការៈ ហើយមិនអាចលោះយកទៅវិញទេ។"* (លេវីវិន័យ ២៧:៣០-៣៣)

ចំណាំថា គ្រប់ដង្វាយ១ភាគ១០គឺ បរិសុទ្ធនៅចំពោះព្រះអម្ចាស់ ហើយ *" បើអ្នកណាចង់លោះអ្វីពី១ភាគ១០ដែលខ្លួនថ្វាយ នោះត្រូវថែម១ភាគក្នុង៥លើសទៅទៀត។"* នេះ មានន័យថា **បើអ្នកណាហូតទុកដង្វាយ១ភាគក្នុង១០ពីព្រះ នោះ១ភាគក្នុង៥ ដែលត្រូវសងវិញ គឺម្តៃភាគរយ (២០%)**។ ម្យ៉ាងទៀត អ្នកសងចំនួននៃ១ភាគក្នុង១០ ដែលបានហូតទុក ថែមការពិន័យ២០% សំរាប់ការសងថ្លៃហូតទុកនៃដង្វាយ១ភាគក្នុង១០។ ចូរចងចាំថា ការនេះត្រូវបានអនុវត្តនៅក្រោមក្រឹត្យវិន័យ។ ប៉ុន្តែសព្វថ្ងៃនេះ នៅក្រោមព្រះគុណយើងបានលឺពីគ្រីស្ទានជាច្រើន(?) ដែលសូមទោស ដោយព្រោះពួកគេមិនអាចមានលទ្ធភាពថ្វាយដង្វាយ១ភាគក្នុង១០ ដោយនិយាយថា ព្រះបានយល់ពីមូលហេតុរបស់ពួកគេហើយ។ ឱខ្ញុំអើយ ចំជាគួរឲ្យអាម៉ាស់មែន!

*"គឺសត្វណាក៏ដោយដែលចូលក្រោមដំបង នោះត្រូវជាដង្វាយ១ភាគក្នុង ១០ទុកជាបរិសុទ្ធដល់ព្រះយេហូវ៉ា"* - គ្រប់របស់ទាំងអស់ ដែលចូលមកក្នុងដៃ របស់អ្នកជឿ ១ភាគក្នុង១០ ត្រូវតែថ្វាយដល់ព្រះ។ អ្វីក៏ដោយដែលមកតាម រយះដៃរបស់អ្នក១ភាគក្នុង១០ គឺត្រូវជារបស់ព្រះហើយគឺវាបរិសុទ្ធ។

**ដង្វាយលើកចុះឡើង ត្រូវឲ្យដល់ពួកលេវី**

*"២១ យើងប្រគល់មួយភាគដប់នៃភោគផលទាំងអស់ នៅស្រុកអ៊ីស្រាអែល អោយកូនចៅលេវី ទុកជាថ្នូរចំពោះកិច្ចការដែលពួកគេធ្វើ នៅក្នុងពន្លាជួបព្រះអម្ចាស់។*

*មិនត្រូវអោយប្រជាជនអ៊ីស្រាអែលចូលមកជិតពន្លាជួបព្រះអម្ចាស់ទៀតឡើយ ក្រែងលោពួកគេទទួលទោស ហើយត្រូវស្លាប់។*

*ពួកលេវីដែលបំរើការងារនៅក្នុង ពន្លាជួបព្រះអម្ចាស់ នឹងទទួលខុសត្រូវលើកំហុសដែលខ្លួនប្រព្រឹត្ត។ នេះជាច្បាប់ដែលត្រូវណែនាំអោយពួកលេវីគ្រប់ជំនាន់ដឹងថា ពួកគេនឹងមិនទទួលចំណែកមត៌កអ្វីក្នុងចំណោមជនជាតិអ៊ីស្រាអែលឡើយ។*

*យើងប្រគល់ភោគផលមួយភាគដប់ ដែលជនជាតិអ៊ីស្រាអែលញែកទុកដោយឡែកសំរាប់យើង អោយកូនចៅលេវី។ ហេតុនេះហើយបានជាយើងប្រកាសអំពីពួកគេថា: "ពួកគេនឹងមិនទទួលចំណែកមត៌កក្នុងចំណោមកូនចៅអ៊ីស្រាអែលឡើយ"។ ជនគណនា ១៨:២១-២៤*

ដង្វាយ១ភាគក្នុង១០របស់ពួកអ៊ីស្រាអែល ដែលបានថ្វាយជាដង្វាយលើកចុះឡើង នោះត្រូវអោយដល់ពួកលេវី។ *"លើកចុះឡើង"* មានន័យថា *"បានលើកឡើងថា បានដកចេញពីចំនួនដ៏ធំ អ្វី១ ដែលបានញែកចេញពីអ្វីផ្សេងទៀតយ៉ាងត្រឹមត្រូវ និងត្រូវឧទ្ទិសដល់ការងាររបស់ព្រះ"*។

**ពួកលេវីត្រូវបង់ដង្វាយ១ភាគក្នុង១០**

*"២៦ ចូរប្រាប់កូនចៅលេវីដូចតទៅ:ពេលណាជនជាតិអ៊ីស្រាអែលនាំយកភោគផលមួយភាគដប់មកអោយអ្នករាល់គ្នាគឺចំណែកដែលយើងប្រគល់អោយអ្នករាល់គ្នា ទុកជាមត៌កនោះ អ្នករាល់គ្នាត្រូវញែកមួយភាគដប់ពីភោគផលមួយភាគដប់ ថ្វាយព្រះអម្ចាស់។*

*តង្វាយមួយភាគដប់ដែលអ្នករាល់គ្នា ញែកទុកដោយឡែកនេះ ត្រូវរាប់ដូចជាតង្វាយ ដែលបងប្អូនរបស់អ្នករាល់គ្នាញែកទុកពីស្រូវ និងស្រាទំពាំងបាយជូររបស់គេដែរ។*

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

*ដូច្នេះ ភោគផលមួយភាគដប់ដែលប្រជាជនអ៊ីស្រាអែលយកមកអោយអ្នករាល់គ្នាអ្នករាល់គ្នា ត្រូវញែកមួយភាគដប់ទុក ថ្វាយព្រះអម្ចាស់។ ត្រូវប្រគល់តង្វាយដែលអ្នករាល់គ្នាញែកថ្វាយព្រះអម្ចាស់ជូនលោកបូជាចារ្យអើរ៉ុន*

*ភោគផលដែលប្រជាជន យកមកជូនអ្នករាល់គ្នានោះ ត្រូវញែកមួយចំណែកថ្វាយព្រះអម្ចាស់ គឺញែកមួយផ្នែកដ៏ល្អវិសេសជាចំណែកសក្ការៈ។*

*ចូរប្រាប់ពួកលេវីថាៈ ពេលណាអ្នករាល់គ្នាញែកផ្នែកដ៏ល្អវិសេសមួយភាគដប់ហើយ ចំណែកដែលនៅសល់ អ្នករាល់គ្នាត្រូវចាត់ទុកដូចជាស្រូវ និងស្រាទំពាំងបាយជូរ ដែលនៅសល់របស់ប្រជាជនដែរ។*

*អ្នករាល់គ្នាបរិភោគភោគផលទាំងនេះ រួមជាមួយគ្រួសាររបស់អ្នករាល់គ្នានៅកន្លែងណាក៏បាន ដ្បិតភោគផលទាំងនេះជាកំរៃសំរាប់ការងារដែលអ្នករាល់គ្នាបំពេញ នៅក្នុងពន្លាជួបព្រះអម្ចាស់។*

*ប្រសិនបើអ្នករាល់គ្នាញែកចំណែកដ៏ល្អវិសេសទុកសំរាប់យើងហើយ អ្នករាល់គ្នានឹងគ្មានបាបនៅពេលបរិភោគចំណែកដែលនៅសល់ អ្នករាល់គ្នាក៏មិនបណ្តាលអោយតង្វាយដ៏វិសុទ្ធរបស់ជនជាតិអ៊ីស្រាអែលក្លាយទៅជាសៅហ្មងហើយអ្នករាល់គ្នាក៏មិនត្រូវស្លាប់ដែរ"។* (ជនគណនា ១៨:២៦-៣២)

ពួកលេវី គឺជាអ្នកធ្វើពន្ធ័កិច្ចរបស់ព្រះ ( អ្នកបំរើការពារព្រះ ) ហើយពួកគេក៏ត្រូវបង់១ភាគ១០ (១០%) នៃដង្វាយលើកចុះឡើង ដែលពួកចៅអ៊ីស្រាអែលបានថ្វាយដែរ។ សល់ប៉ុន្មានពួកគេយកទៅប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេដូចជាបែកចែកនៅក្នុងខ៣១ ពីព្រោះនេះជារង្វាន់របស់ពួកគេ នៅក្នុងរោងឧបោសថនៃក្រុមជំនុំ ។

## ហេសេគាស្តារការថ្វាយដង្វាយ១ភាគក្នុង១០ឡើងវិញ

នៅក្នុងប្រវត្តិសាស្ត្ររបស់ពួកសាសន៍យូដា មានមនុស្សជាច្រើន បានភ្លេចក្រឹត្យវិន័យនៃការថ្វាយដង្វាយ១ភាគក្នុង១០ ហើយមិនបានថ្វាកិត្តិយសដល់ព្រះ ដោយធ្វើមិនដឹងមិនឮពីការ ថ្វាយដង្វាយ១ភាគក្នុង១០។ ទោះបីយ៉ាងណាក៏ដោយ សូមយើងអាន ២របាក្សត្រ៣១:២-១២ ពីរបៀបស្តេច ហេសេគា បានតាំងគំរូផ្ទាល់ខ្លួន ហើយបានស្តារការប្តេជ្ញារបស់ប្រជារាស្ត្រ ឲ្យអនុវត្តការដង្វាយ១ភាគក្នុង១០ឡើងវិញ។

*"ព្រះបាទហេសេគាបាន តែងតាំងក្រុមបូជាចារ្យ និងក្រុមលេវីតាមជាន់ថ្នាក់ អោយបំពេញមុខងាររបស់គេរៀងៗខ្លួនវិញ គឺក្រុមបូជាចារ្យ និងក្រុមលេវីដែលបំពេញមុខងារថ្វាយតង្វាយដុត*ទាំងមូល និងយញ្ញបូជាមេត្រីភាព ព្រមទាំងអ្នកដែលបំរើការងារក្នុងព្រះវិហារ អ្នកចំរៀងសំរាប់លើកតម្កើងព្រះអម្ចាស់ និងអ្នកយាមទ្វារពន្លារបស់ព្រះអម្ចាស់។*

*ព្រះរាជាបានយក រាជទ្រព្យមួយចំណែក សំរាប់បង់ចំណាយទៅលើតង្វាយដុតទាំងមូល ដែលត្រូវថ្វាយនៅពេលព្រឹក នៅពេលល្ងាច នៅថ្ងៃសប្ប័ទ* នៅបុណ្យដើមខែ និងបុណ្យដ៏សំខាន់ៗផ្សេងទៀត ដូចមានចែងទុកក្នុងក្រឹត្យវិន័យរបស់ព្រះអម្ចាស់។*

*ព្រះរាជាបង្គាប់ប្រជាជន និងអ្នកក្រុងយេរូសាឡឹម អោយប្រគល់ចំណែករបស់ក្រុមបូជាចារ្យ និងក្រុមលេវីទៅពួកគេ ធ្វើដូច្នេះ ពួកគេមិនខ្វល់ខ្វាយនឹងអ្វីផ្សេងទៀត ក្រៅពីគិតដល់ក្រឹត្យវិន័យរបស់ព្រះអម្ចាស់។*

*ពេលប្រជាជនអ៊ីស្រាអែលទទួលបញ្ជារបស់ស្ដេចហើយ ពួកគេនាំយកផលដំបូងនៃស្រូវ ស្រាទំពាំងបាយជូរថ្មី ប្រេង ទឹកឃ្មុំ និងផលដំណាំផ្សេងៗទៀតយ៉ាងច្រើនបរិបូណ៌ ហើយពួកគេក៏នាំយកមួយភាគដប់នៃអ្វីៗដែលខ្លួនមានមកថ្វាយយ៉ាងបរិបូណ៌ដែរ។*

*កូនចៅអ៊ីស្រាអែល និងកូនចៅយូដាដែលរស់នៅតាមក្រុងនានា ក្នុងស្រុកយូដា បាននាំគោ និងចៀមមកថ្វាយជាតង្វាយមួយភាគដប់ ហើយគេក៏យកអ្វីៗទាំងអស់ ដែលញែកជាសក្ការៈថ្វាយដល់ព្រះអម្ចាស់ជាព្រះរបស់ខ្លួនមកថ្វាយជាតង្វាយមួយភាគដប់ដែរ។ គេដាក់តង្វាយទាំងនោះជាច្រើនគំនរ។*

*គេបានចាប់ផ្ដើមប្រមូលតង្វាយមកដាក់ជាគំនរ ចាប់ពីខែទីបី រហូតដល់ខែទីប្រាំពីរ។ព្រះបាទហេសេគា និង ពួកមន្ត្រីមកមើលគំនរតង្វាយទាំងនោះ ហើយនាំគ្នាអរព្រះគុណព្រះអម្ចាស់និងអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ*

*ព្រះបាទហេសេគាសាកសួរក្រុមបូជាចារ្យ និង ក្រុមលេវី ស្ដីអំពីគំនរតង្វាយទាំងនោះ។*

*លោកមហាបូជាចារ្យអសារាពីអំបូរសាដុកទូលស្ដេចថាៈ ចាប់ពីពេលប្រជាជននាំតង្វាយដែលគេបានញែកទុក មកដាក់ក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ នោះយើងមានអាហារបរិភោគយ៉ាងបរិបូណ៌ ថែមទាំងនៅសេសសល់ជាច្រើនឥតគណនាផង ដ្បិតព្រះអម្ចាស់ប្រទានពរដល់ប្រជារាស្ត្ររបស់ព្រះអង្គ។ អ្វីៗដែលគរនៅទីនេះ សុទ្ធតែជារបស់ដែលយើងមានលើសពីសេចក្ដីត្រូវការ។*

*ព្រះបាទហេសេគាបង្គាប់ អោយគេរៀបចំបន្ទប់ នៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់។*

*ពេលរៀបចំរួចស្រេចហើយ គេក៏នាំយកតង្វាយដែលគេបានញែកទុកដោយឡែក និងតង្វាយមួយភាគដប់ ព្រមទាំងតង្វាយដ៏សក្ការៈផ្សេងទៀតយកមកទុកក្នុងបន្ទប់នោះជាប្រក្រតី។*

*លោកកូណានាជាក្រុមលេវី មានភារកិច្ចមើលខុសត្រូវ លើតង្វាយទាំងនោះ ដោយមានលោកស៊ីម៉ៃ ជាប្អូនរបស់គាត់ ជាអ្នកជំនួយការ។"*

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

មានមេរៀនដ៏អស្ចារ្យមួយនៅក្នុងអត្ថបទ ព្រះគម្ពីរនេះ សំរាប់គ្រីស្ទបរិស័ទទាំងអស់។នៅពេលប្រជាជនទាំងមូលនាំយកតង្វាយមកក្នុងព្រះដំណាក់របស់ព្រះអម្ចាស់លោកបូជាចារ្យអ័សារាយ៉ាមានប្រសាសន៍ថា៉ យើងមានអាហារបរិភោគគ្រប់គ្រាន់ហើយ យើងមានស្បៀងអាហារ គ្រប់គ្រាន់ហើយ ដ្បិតព្រះអម្ចាស់បានប្រទានពរប្រជាជនរបស់ទ្រង់ហើយអ្វីៗនៅសល់ គឺ នៅក្នុងឃ្លាំងដ៏អស្ចារ្យនេះ៉។ ព្រះវិហារជាច្រើនសព្វថ្ងៃនេះត្រូវ គេលក់នំឃុកឃី 'hot dogs' និងហាំប៊ឺហ្គឺរ ឬរៀបចំការលក់ការអ៊្រូទាំ ដើម្បីនាំមកនូវប្រាក់ចំណូល បន្ថែមដើម្បីបំពេញ នូវកង្វះខាតដង្វាយមួយភាគក្នុងដប់និងដង្វាយផ្សេងៗ។ប្រជាជនគ្រាន់តែបដិសេធមិន៉បង់៉នូវអ្វីដែលជារបស់ព្រះ។ ពួកគេជាចោរប្លន់នៃដង្វាយមួយភាគក្នុងដប់របស់ព្រះ។ នោះជាអ្វីដែលព្រះបានមានបន្ទូលនៅក្នុងម៉ាឡាគី ៣ ថា ៉*ព្រះអង្គបានប្លន់ទូលបង្គំដោយយកមួយភាគដប់និងតង្វាយផ្សេងៗ*៉។ ផ្តល់ឱ្យទៅព្រះនូវអ្វីដែលជាកម្មសិទ្ធិរបស់ទ្រង់ហើយអ្នកនឹងមិនត្រូវលក់អ្វីទាំងអស់ដើម្បីគាំទ្រដល់ពន្ធ័កិច្ចរបស់ព្រះឡើយ។

**នេហេមា និងការថ្វាយដង្វាយ១ភាគក្នុង១០ បានទុកនៅក្នុងព្រះវិហារ**

*៉ពួកយើងជាបូជាចារ្យ ក្រុមលេវី និងប្រជាជន បានចាប់ឆ្នោតដាក់វេនគ្នាឧបត្ថម្ភអុស សំរាប់ព្រះដំណាក់របស់ព្រះនៃយើង គឺរៀងរាល់ឆ្នាំយើងត្រូវយកអុសមកជាតង្វាយតាមអំបូរ តាមពេលកំណត់ ដើម្បីដុតនៅលើអាសនៈរបស់ព្រះអម្ចាស់ ជាព្រះនៃយើង ដូចមានចែងទុកក្នុងក្រឹត្យវិន័យ។*

*៣៥ យើងក៏សន្យាយកផលដំបូងនៃស្រែចំការ និងផ្លែឈើទាំងប៉ុន្មានមកថ្វាយនៅក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ ជារៀងរាល់ឆ្នាំដែរ។ យើងនឹងនាំកូនប្រុសច្បងរបស់យើងមកថ្វាយព្រះអម្ចាស់ ហើយក៏នាំកូនដំបូងនៃហ្វូងចៀម និងហ្វូងគោរបស់យើងមកថ្វាយព្រះអង្គ ដូចមានចែងទុកក្នុងក្រឹត្យវិន័យ គឺយើងនឹងនាំមកជូនក្រុមបូជាចារ្យ ដែលបំរើការងារនៅក្នុងព្រះដំណាក់របស់ព្រះនៃយើង។*

*យើងនឹងនាំម្សៅដំបូងរបស់យើង ព្រមទាំងតង្វាយដែលយើងបានញែកទុកដោយឡែក គឺមានផ្លែឈើគ្រប់មុខស្រាទំពាំងបាយជូរថ្មី និងប្រេងមកជូនក្រុមបូជាចារ្យ នៅក្នុងបន្ទប់អមនៃព្រះដំណាក់របស់ព្រះនៃយើង។ យើងនឹងយកភោគផលពីដីរបស់យើងមួយភាគដប់ ជូនក្រុមលេវី។ ក្រុមលេវីត្រូវទៅប្រមូលយកផលទាំងនោះពីស្រុកភូមិ ដែលមានស្រែចំការរបស់យើង។*

*ពេលក្រុមលេវីនាំយកតង្វាយ មួយភាគដប់ចូលមក បូជាចារ្យមួយរូបដែលជាពូជពង្សរបស់លោកអើរ៉ុន ត្រូវទៅជាមួយ ហើយទទួលយកមួយភាគដប់នៃតង្វាយមួយភាគដប់នោះ ទៅទុកក្នុងឃ្លាំងនៃព្រះដំណាក់របស់ព្រះនៃយើង។*

*ជនជាតិអ៊ីស្រាអែល និងក្រុមលេវី ត្រូវយកតង្វាយដែលគេបានញែកទុកដោយឡែក មកទុកក្នុងបន្ទប់ទាំងនោះ គឺមានស្រូវ ស្រាទំពាំងបាយជូរថ្មី និងប្រេង។ ក្នុងបន្ទប់ទាំងនោះ គេដាក់វត្ថុប្រើប្រាស់ក្នុងទីសក្ការៈ ហើយក្រុមបូជាចារ្យដែលត្រូវវេនបំពេីការងារក្រុមយាមទ្វារ និងក្រុមចំរៀងក៏ស្ថិតនៅក្នុងបន្ទប់នោះដែរ។ ដូច្នេះ យើងពុំបោះបង់ចោលព្រះដំណាក់របស់ព្រះនៃយើងឡើយ។"*(នេហេមា ១០:៣៤-៣៩)

តើពួកលេវីនាំយកដង្វាយ១ភាគ១០ទៅឯណា? ***"នាំយកទៅឯ ព្រះវិហារនៃព្រះរបស់យើង"*** ពិតមែន! គ្រីស្ទានខ្លះបានចោទប្រកាន់គ្រូអធិប្បាយដោយលោកអធិប្បាយពីម៉ាឡាគី ៣:៩-១០ ដើម្បីបំភ័យប្រជាជនឲ្យថ្វាយអស់លុយរបស់ពួកគេទៅវិហារ។ ពួកគេបានបដិសេធថា ខទាំង២នេះ មិនមែនសំដៅទៅលើពួកជំនុំគ្រីស្ទាន ជារូបកាយរបស់ព្រះគ្រីស្ទទេ។

**មាឡាគី - "ដង្វាយ១ភាគ១០ នឹងដង្វាយស្ម័គ្រពីចិត្ត"**

*"យើងជាព្រះអម្ចាស់ យើងមិនប្រែប្រួលទេរីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នានៅតែជាកូនចៅយ៉ាកុបដដែល។*

*ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថាអ្នករាល់គ្នាក៏ដូចដូនតារបស់អ្នករាល់គ្នាដែរអ្នករាល់គ្នាងាកចេញពីច្បាប់របស់យើងគឺអ្នករាល់គ្នាមិនព្រមកាន់តាមទេ។ចូរនាំគ្នាវិលមករកយើងនោះយើងក៏វិលមករកអ្នករាល់គ្នាវិញដែរ។អ្នករាល់គ្នាពោលថា:"យើងខ្ញុំត្រូវវិលមកវិញយ៉ាងដូចម្ដេច?"។*

**តើមនុស្សកេងប្រវ័ញ្ចព្រះជាម្ចាស់ដូចម្ដេចបាន?អ្នករាល់គ្នាកេងប្រវ័ញ្ចយើង** ហើយពោលថា"យើងខ្ញុំកេងប្រវ័ញ្ចព្រះអង្គដូចម្ដេចខ្លះ?។ **គឺអ្នករាល់គ្នាកេង** ប្រវ័ញ្ចតង្វាយមួយភាគដប់ និងតង្វាយដែលអ្នករាល់គ្នាត្រូវញែកទុកសំរាប់យើង!

អ្នករាល់គ្នាត្រូវបណ្ដាសាហើយ!ព្រោះប្រជាជាតិទាំងមូលបានកេងប្រវ័ញ្ចយើង។

*ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា«ចូរនាំយកតង្វាយមួយភាគដប់ទាំងប៉ុន្មានមកដាក់នៅក្នុងឃ្លាំងដើម្បីអោយមានស្បៀងអាហារក្នុងដំណាក់របស់យើង។ចូរធ្វើយ៉ាងនេះ ដើម្បីល្បងលយើងទៅនោះអ្នករាល់គ្នានឹងឃើញថាយើងនឹងបើកផ្ទៃមេឃបង្ហូរព្រះពរដ៏លើសលប់មកលើអ្នករាល់គ្នា។*

*ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា«យើងនឹងរារាំងសត្វល្អិតមិនអោយបំផ្លាញដំណាំរបស់អ្នករាល់គ្នាហើយចំការទំពាំងបាយជូររបស់អ្នករាល់គ្នានឹងផ្ដល់ភោគផលបរិបូណ៌។*

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

*ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា«ប្រជាជាតិទាំងអស់នឹងពោលថាអ្នករាល់គ្នាពិតជាមានសុភមង្គលមែនដ្បិតស្រុករបស់អ្នករាល់គ្នានឹងទៅជាស្រុកមួយដ៏សម្បូណ៌សប្បាយ។"* (មាឡាគី ៣:៦-១២)

*"ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា ចូរនាំយកតង្វាយមួយភាគដប់ទាំង ប៉ុន្មាន មកដាក់នៅក្នុងឃ្លាំងដើម្បី អោយមានស្បៀងអាហារក្នុងដំណាក់របស់យើង។* ខនេះប្រាប់យើង យ៉ាងច្បាស់ថាត្រូវនាំយកដង្វាយមួយភាគក្នុងដប់ទៅកន្លែងថ្វាយបង្គំធម្មតារបស់យើង។

*"អ្នករាល់គ្នាត្រូវតែទៅថ្វាយបង្គំព្រះអម្ចាស់ នៅកន្លែងដែលព្រះអង្គបានជ្រើសរើស ក្នុងទឹកដីនៃ កុលសម្ព័ន្ធទាំងអស់របស់អ្នករាល់គ្នា ទុកជាព្រះដំណាក់ សំរាប់សំដែងព្រះនាមរបស់ព្រះអង្គ។*

*ត្រូវយកតង្វាយដុតទាំងមូល* យញ្ញបូជា តង្វាយមួយភាគដប់ តង្វាយពិសេស តង្វាយលាបំណន់ ឬតង្វាយស្ម័គ្រចិត្ត ព្រមទាំងកូនដំបូងនៃហ្វូងគោ និងហ្វូងចៀមរបស់អ្នករាល់គ្នា ទៅថ្វាយព្រះអង្គនៅកន្លែងនោះ។ ដរាបណាអ្នករស់នៅលើទឹកដីរបស់អ្នក ចូរប្រយ័ត្ន កុំបំភ្លេចពួកលេវីឡើយ។"*

តើព្រះអម្ចាស់ដាក់នាមទ្រង់នៅ**កន្លែងណា**? តើ ***"កន្លែងនោះ"*** ដែលទ្រង់បានដាក់ព្រះនាមទ្រង់នៅឯណា? **កន្លែងនោះគឺនៅព្រះបន្ទូល ជាកន្លែងព្រះអម្ចាស់គង់នៅ ដែលគង់នៅក្នុងព្រះនាមព្រះអម្ចាស់ (យេស៊ូ)!** *"ត្បិតកន្លែងណាដែលមាន២ ឬ៣នាក់ ប្រជុំជាមួយគ្នា ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនូវកណ្តាលចំណោមអ្នកទាំងនោះដែរ"* (ពួកអ្នកជឿ ពួកជំនុំក្នុងស្រុក) ម៉ាថាយ ១៨: ២០។ ហើយដរាបណាមានពួកលេវីរស់នៅលើផែនដី នោះពួកគេមិនត្រូវបានបោះបង់ ឬ មិនដឹងមិនឮឡើយ។

ព្រះមានសេចក្តីសន្យាយ៉ាងពិសេសសំរាប់អ្នកជឿ បើសិនជាគាត់ ឬនាងនឹងស្តាប់បង្គាប់តាមបញ្ញត្តិរបស់ទ្រង់ ។ អញនឹងបើកទ្វារស្ថានសួគ៌ ដើម្បីចាក់ព្រះពរមកលើឯងដែលនឹងគ្មានកន្លែងល្មមនឹងទុកបានទេ " -ម៉ាឡាគី ៣:១០៖

ព្រះពរនៃព្រះក្លាយជាការពិតដល់អស់អ្នកដែលជឿ:
*"ប្រសិនបើអ្នកយកចិត្តទុកដាក់ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ដោយកាន់ និងប្រតិបត្តិតាមបទបញ្ជាទាំងប៉ុន្មានរបស់ព្រះអង្គ ដូចខ្ញុំបង្គាប់នៅថ្ងៃនេះព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងប្រទានអោយអ្នកបានទៅជាប្រជាជាតិមួយ ប្រសើរជាងប្រជាជាតិទាំងអស់នៅលើផែនដី។ ប្រសិនបើអ្នកស្តាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ ជាព្រះរបស់អ្នក ព្រះអង្គនឹងប្រទានពរគ្រប់យ៉ាងដល់អ្នក*

*គឺព្រះអង្គប្រទានពរដល់អ្នក នៅតាមទីក្រុង ព្រះអង្គប្រទានពរដល់អ្នក នៅតាមស្រែចំការ។*

*ព្រះអង្គប្រទានពរអោយអ្នកមានកូនចៅច្រើន អោយដីរបស់អ្នកកើនភោគផលបរិបូណ៌ ហើយហ្វូងសត្វរបស់អ្នក គឺគោ និងចៀមក៏នឹងកើនចំនួនឡើងជាច្រើនដែរ។*

*ព្រះអង្គប្រទានពរអោយអ្នកមានផ្លែឈើពេញល្អី ព្រមទាំងមានស្រូវពេញជង្រុក។*

*ព្រះអង្គនឹងប្រទានពរដល់អ្នក ក្នុងគ្រប់កិច្ចការដែលអ្នកធ្វើ។*

*ព្រះអម្ចាស់នឹងធ្វើអោយបច្ចាមិត្តបាក់ទ័ព រត់នៅពីមុខអ្នក។ ពួកគេចេញមកវាយអ្នក ដោយដើរតាមផ្លូវតែមួយ តែពួកគេនឹងរត់នៅមុខអ្នក ទៅតាមផ្លូវប្រាំពីរ។*

*ព្រះអម្ចាស់ប្រទានពរអោយអ្នកមានស្រូវពេញជង្រុក ហើយអ្វីៗដែលអ្នកធ្វើ ព្រះអង្គប្រទានពរជានិច្ច។ ព្រះអម្ចាស់ ជាព្រះរបស់អ្នក នឹងប្រទានពរអ្នកក្នុងស្រុកដែលព្រះអង្គប្រទានអោយអ្នក។*

*ពេលណាអ្នកប្រតិបត្តិតាមបទបញ្ជារបស់ព្រះអម្ចាស់ ជាព្រះនៃអ្នក ហើយដើរតាមមាគ៌ារបស់ព្រះអង្គ នោះព្រះអម្ចាស់ នឹងធ្វើអោយអ្នកទៅជាប្រជារាស្ត្រដ៏វិសុទ្ធ* ដូចព្រះអង្គបានសន្យាជាមួយអ្នក។*

*ជាតិសាសន៍ទាំងអស់នៅលើផែនដីនឹងឃើញថា ព្រះអម្ចាស់បានជ្រើសរើសអ្នកជាប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ ហើយពួកគេនឹងកោតខ្លាចអ្នក។*

*ព្រះអម្ចាស់ជាព្រះរបស់អ្នក នឹងប្រទានអោយអ្នកបានចំរុងចំរើន ដោយធ្វើអោយពូជពង្សរបស់អ្នក និងហ្វូងសត្វរបស់អ្នកកើនចំនួនច្រើនឡើង ហើយក៏ធ្វើអោយអ្នកទទួលភោគផលជាច្រើន នៅលើទឹកដីដែលព្រះអង្គបានសន្យាដល់បុព្វបុរស* ថាប្រទានអោយអ្នកដែរ។*

*ព្រះអម្ចាស់នឹងបើកផ្ទៃមេឃ បង្អុរភ្លៀងចុះមកស្រោចស្រពទឹកដីរបស់អ្នកតាមរដូវកាល ដើម្បីប្រទានពរដល់កិច្ចការទាំងប៉ុន្មានដែលអ្នកធ្វើ។ អ្នកនឹងអោយទ្រព្យដល់ប្រជាជាតិជាច្រើនខ្ចី តែអ្នកមិនខ្ចីពីគេឡើយ។*

ព្រះអម្ចាស់ជាព្រះរបស់អ្នក នឹងធ្វើអោយអ្នកបានថ្កុំថ្កើងជាងគេ គឺមិនមែនអន់ជាងគេទេ អ្នកនឹងទទួលកិត្តិយសខ្ពង់ខ្ពស់ជានិច្ច គឺមិនចុះអោនថយឡើយ។ ប៉ុន្តែ អ្នកត្រូវស្តាប់បង្គាប់ ហើយកាន់ និងប្រតិបត្តិតាមបទបញ្ជារបស់ព្រះអង្គ ដែលខ្ញុំប្រគល់អោយអ្នកនៅថ្ងៃនេះ។

*មិនត្រូវងាកទៅឆ្វេង ទៅស្តាំ ឆ្ងាយពីបទបញ្ជាទាំងប៉ុន្មាន ដែលខ្ញុំប្រគល់អោយអ្នកនៅថ្ងៃនេះ ហើយបែរទៅជំពាក់ចិត្ត និងគោរពថ្វាយបង្គំព្រះឯទៀតៗឡើយ"*(ចោទិយកថា ២៨:១-១៤)

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

## ២. ការថ្វាយដង្វាយ១ភាគក្នុង១០ នឹងដង្វាយស្មគ្រ័ពីចិត្ត មិនបានចប់នៅក្រោមសញ្ញាថ្មីទេ

### ក្រឹត្យវិន័យ និងព្រះគុណ

មានសៀវភៅជាច្រើនអំពីការថ្វាយដង្វាយ១ភាគក្នុង១០ ដែលអ្នកនិពន្ធទាំងនោះ បានដកស្រង់បទគម្ពីរជាក់លាក់មួយចំនួនមក ហើយអធិប្បាយពីបទគម្ពីរទាំងនោះ។ អ្នកមិនអាចធ្វើអញ្ចឹងបានទេ អ្នកត្រូវតែមើលគ្រប់ទាំងព្រះបន្ទូលរបស់ព្រះ ទាក់ទងនឹងគោលលទ្ធិ ( សេចក្តីបង្រៀន ) ដែលអ្នកកំពុងតែនិយាយ ។ **អ្នកមិនអាចចេញឆ្ងាយពីសេចក្តីពិតទេ ។**

តើការថ្វាយដង្វាយ១ភាគក្នុង១០ ត្រូវអនុវត្តតែនៅក្នុង គ្រាសញ្ញាចាស់ប៉ុណ្ណោះឬ? តើការថ្វាយដង្វាយ១ភាគក្នុង១០ ត្រូវបានលុបចោល នៅពេលចាប់ផ្តើមមានសញ្ញាថ្មីឬ? បើសិនជាឆ្លើយថា "បាទ" អញ្ចឹងហេតុអ្វីបានជាយើងមានបទគម្ពីរនៅសញ្ញាថ្មី ដែលបញ្ជាក់ថាការថ្វាយដង្វាយ១ភាគក្នុង១០មានពិតមែន?

មានអ្នកខ្លះបាននិយាយថា ការថ្វាយដង្វាយនេះអនុវត្តសំរាប់តែពួកយូដាទេ ប៉ុន្តែគេមិនអាចចង្អុលភស្តុតាងនៅក្នុងបទគម្ពីរបានទេ។ ព្រះបន្ទូលនៃព្រះត្រូវតែជាអ្នកដឹកនាំយើង ឲ្យដោះស្រាយគ្រប់បញ្ហាទាំងអស់។ យើងត្រូវតែកាត់ស្រាយបទគម្ពីរអោយបានត្រឹមត្រូវតាមសេចក្តីពិត។ ដោយមានការនេះក្នុងគំនិត ចូរយើងមើលបទគម្ពីរសិន ។

យើងត្រូវតែស្គាល់អំពីបទគម្ពីរឲ្យបានច្បាស់ថា កន្លែងខ្លះនិយាយសំដៅទៅលើតែសាសន៍យូដា សាសន៍ដទៃឬវិហារនៃព្រះ - "សូមបងប្អូនកុំធ្វើអោយសាសន៍យូដា សាសន៍ក្រិក ឬក្រុមជំនុំ *របស់ព្រះជាម្ចាស់ ជំពប់ចិត្តឡើយ។ ..." (១កូរិនថូ១០:៣២)។ ទោះបីជាគម្ពីរបានចែងសំរាប់មនុស្សគ្រប់ជាន់ថ្នាក់ក៏ដោយ ហើយសំរាប់ឲ្យពួកគេរៀន ក៏មិនសង្កត់ធ្ងន់ទៅលើគ្រប់មនុស្សជាតិទូរទៅដែរ។ ផ្នែកខ្លះនិយាយអំពីសាសន៍យូដា ខ្លះនិយាយអំពីសាសន៍ដទៃ នឹងខ្លះទៀតសំដៅទៅលើពួកជំនុំ។ ទាំងនេះ គេបែងចែកវណ្ណៈ នៃមនុស្សជាតិ ជា៣ផ្នែកធំៗ។ រីឯគម្ពីរទាំងមូលបានចែងមកសំរាប់តែតំរង់ពួកជំនុំ វាមិនមែនគ្រាន់តែចែងអំពីពួកជំនុំប៉ុណ្ណោះទេ។

តើបងប្អូនកត់សំគាល់ទេថា អស់ទាំងក្រឹត្យវិន័យ១០ប្រការ ត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងសញ្ញាថ្មី លើកលែងតែប្រការទី៤ ដែលទាក់ទងនិងថ្ងៃឈប់សំរាកឬទេ? ( រ៉ូម៖១៣:៨-១០ , អេភូសូរ ៦:១-២ ,យ៉ាកុប ៥:១២, ១យ៉ូហាន ៥:២១ ) ហេតុអ្វីបានជាព្រះលុបក្រឹត្យវិន័យទី៤ចោល បើសិនជាទ្រង់ចង់អោយពួកជំនុំដើរតាមក្រឹត្យវិន័យនោះ? បើសិនជាព្រះចង់ឲ្យពួកជំនុំនៅ

ក្រោមសេចក្តីសញ្ញាថ្មី ធ្វើការអ្វីពិតប្រាកដ ទ្រង់ពិតជាបង្ហាញអោយយើងដឹង។ ការថ្វាយដង្វាយ១ភាគក្នុង១០ គឺជាសេចក្តីពិត ដែលព្រះអម្ចាស់យេស៊ូមិនបានលុបចោលទេ ព្រោះទ្រង់ចង់អោយពួកជំនុំបន្តអនុវត្ត និងដើម្បីឲ្យបានទទួលសេចក្តីសន្យាដោយសារការថ្វាយនោះ ។

គម្ពីរបានចែងប្រាប់យើងថា ទោះជាយើងជាពួកសាសន៍ដទៃខាងសាច់ឈាម ក៏យើងជាពួកសាសន៍យូដាខាងវិញ្ញាណនៅក្នុងព្រះគ្រីស្ទដែរ។ " ......" ( រ៉ូម ២:២៨-២៩ )។ លើសពីនេះទៅទៀត ក្នុងនាមជាពួជសាសន៍ដទៃ យើងត្រូវបានផ្សាំភ្ជាប់ជាមួយនឹងដើមអូលីវ នឹងក្លាយជាអ្នករួមចំណែកព្រះពរខាងវិញ្ញាណដែរ។ ទាក់ទងនឹងបញ្ហានេះ លោកប៉ុលបាននិយាយថា *"សាសន៍អ៊ីស្រាអែលប្រៀបបីដូចជាដើមអូលីវ ដែលគេកាត់មែកខ្លះចោល រីឯអ្នកវិញ អ្នកប្រៀបបីដូចជាមែកអូលីវព្រៃ ត្រូវគេយកមកផ្សាំជំនួសមែក ដែលគេកាត់ចោលនោះ។ ឥឡូវនេះ អ្នកស្រូបយកជីជាតិពីឫសរួមជាមួយមែកឯទៀតៗដែរ... ប្រហែលជាអ្នកពោលថា ព្រះជាម្ចាស់បានកាត់មែកទាំងនោះចោល ដើម្បីយកខ្ញុំមកផ្សាំជំនួស!"* (រ៉ូម១១:១៧,១៩)។ មែកខ្លះ "សំដៅទៅលើពួកអ៊ីស្រាអែលដែលត្រូវកាច់ចេញ ដោយព្រោះមិនបានជឿ" (រ៉ូម១១:២០) និងខ្នែង "អូលីវព្រៃ" សំដៅទៅលើពួកសាសន៍ដទៃដែលត្រូវបានផ្សាំជាមួយដើមអូលីវស្រុក។

ព្រះយេស៊ូបានមានបន្ទូលថា *"ខ្ញុំជាដើមទំពាំងបាយជូរ ឯអ្នករាល់គ្នាជាខ្នែង"* (យ៉ូហាន១៥:៥ខ) យើងដឹងថា ពួកជំនុំបានក្លាយជាអ្នករួមចំណែកជាមួយដើមទំពាំងបាយជូរដូចគ្នាដូច្នេះ យើងអាចសន្និដ្ឋានថា ការអនុវត្តនៃការថ្វាយដង្វាយ១ភាគ១០ ដែលពួកសាសន៍យូដាខាងសាច់ឈាមបានធ្វើនោះពួកសាសន៍យូដាខាងវិញ្ញាណដែលជាអវៈយវៈនៃពួកជំនុំរបស់ព្រះ ក៏ត្រូវថ្វាយដង្វាយ១ភាគ១០ដែរ។ ព្រះគម្ពីរមិនបានចែងថា ឈប់ថ្វាយដង្វាយ១ភាគក្នុង១០ទេ នៅពេលដែលចូលសម័យព្រះគុណជំនួសសម័យក្រឹត្យវិន័យនោះ។ ប៉ុន្តែសញ្ញាថ្មីនិយាយបញ្ជាក់ឡើងវិញ និងបានបង្រៀនយើងថា អ្នកជឿគួរតែថ្វាយដង្វាយ១ភាគ១០។

## ៣-ការថ្វាយដង្វាយ១ភាគក្នុង១០ នៅក្នុងសញ្ញាថ្មី

### ពួកអ្នកដឹងនាំខាងសាសនា

*"ពួកអាចារ្យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាយកជីរអង្កាម ជីរនាងវង និងម្អមមួយភាគដប់មកថ្វាយព្រះជាម្ចាស់ ប៉ុន្តែ អ្នករាល់គ្នាលះបង់ក្រឹត្យវិន័យ*សំខាន់ៗចោល មានសេចក្តីសុចរិត មេត្តាករុណាធម៌ និងជំនឿស្មោះត្រង់ជាដើម។ វិន័យទាំងប៉ុន្មានប្រការ*

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

*នេះហើយ ដែលអ្នករាល់គ្នាត្រូវប្រតិបត្តិតាមដោយឥតលះបង់ចោលប្រការឯទៀតៗ។*(ម៉ាថាយ ២៣:២៣)

ព្រះយេស៊ូគ្រីស្ទបានស្តីបន្ទោសពួកអាចារ្យ និងពួកផារិស៊ី ដែលជាអ្នកដឹកនាំខាងសាសនា នៅសម័យរបស់ទ្រង់ ដោយព្រោះពួកគេជាមនុស្សមានពុត។ ទ្រង់មិនបានប្រឆាំងនិងការថ្វាយដង្វាយ១ភាគ១០ទេ ប៉ុន្តែទ្រង់បានបន្ថែមថា "*ការទាំងអស់នេះក៏អ្នកត្រូវធ្វើដែរ.....*" អ្នកខ្លះនិយាយថា ព្រះយេស៊ូកំពុងតែនិយាយទៅកាន់ពួកសាសន៍យូដា។ បើសិនជាអញ្ចឹងមែននោះ តើកន្លែងណា ដែលបញ្ជាក់ថា ពួកយើងដែលជាពួកជំនុំព្រះដ៏មានព្រះជន្មរស់លែងថ្វាយដង្វាយ១ភាគ១០?

ព្រះបានចាត់សាវកប៉ូលឲ្យទៅពួកសាសន៍ដទៃ ហើយគាត់បានសរសេរសំបុត្រ១៤ច្បាប់ដល់ពួកជំនុំ ហើយនៅពេលខ្លះគាត់បាននិយាយទៅកាន់ពួកសាសន៍យូដាផ្ទាល់។ តើយើងក្នុងនាមជាសាន៍យូដាខាងវិញ្ញាណ មិនបានទទួលការទូន្មានពីសំបុត្រ១៤ច្បាប់ ដែលបានសរសេរផ្ញើទៅពួកជំនុំទេឬអ្វី? ជាការពិត យើងបានទទួលការទូន្មានពីសំបុត្រទាំងនោះ អាម៉ែន២កាក់!

**២កាក់**

*"ព្រះយេស៊ូគង់នៅមុខហិបតង្វាយ ព្រះអង្គទតមើលរបៀបដែលបណ្តាជនយកប្រាក់មកដាក់ក្នុងហិបនោះ។ អ្នកមានច្រើននាក់ដាក់ប្រាក់ជាច្រើន។*

*មានស្ត្រីមេម៉ាយក្រីក្រម្នាក់មកដល់ នាងយកប្រាក់ពីរសេនជាចំនួនដ៏តិចតួចបំផុត ដាក់ក្នុងហិបតង្វាយនោះដែរ។*

*ព្រះយេស៊ូត្រាស់ហៅពួកសិស្ស*មក ហើយមានព្រះបន្ទូលទៅគេថា «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាបានដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះបានដាក់ប្រាក់ក្នុងហិបច្រើនជាងគេទាំងអស់*

*ដ្បិតពួកអ្នកទាំងនោះយកប្រាក់សំណល់ របស់ខ្លួនមកដាក់។ រីឯស្ត្រីមេម៉ាយនេះវិញ ទោះបីនាងក្រីក្រយ៉ាងណាក៏ដោយ ក៏នាងបានយកប្រាក់ដែលនាងត្រូវការជាចាំបាច់មកដាក់ដែរ គឺប្រាក់ទាំងប៉ុន្មានដែលនាងមានសំរាប់ចិញ្ចឹមជីវិត"។* ម៉ាកុស ១២: ៤១-៤៤ ;លូកា ២១:១-៤

**ការបង្រៀនរបស់សាវកប៉ូល**

សាវកប៉ូល បាននិយាយយ៉ាងច្បាស់លាស់និងបញ្ហានៃការថ្វាយរបស់គ្រីស្ទាន ដែលមានចែកនៅក្នុងសំបុត្រមួយចំនួនរបស់គាត់។ គាត់បានសរសេរអស់ពីជំពូក នៅក្នុង២កូរិនថូសទាក់ទងនេងប្រធានបទនេះ ។ នៅក្នុង១កូរិនថូស ៩ ប៉ូលបានប្រកាសថា ពួកអ្នកដែលបំរើការខាងវិញ្ញាណ គួរតែអោយអ្នកជឿតាមរយៈពួកគេ ឧបត្ថម្ភដល់ពួកគេ។ "*មិនដែលមាននរណាបំរើកងទ័ពហើយចេញសោហ៊ុយខ្លួនឯងឡើយ មិនដែលមាននរណាដាំទំពាំងបាយជូរ*

*ហើយមិនបរិភោគផ្លែនោះទេ ក៏មិនដែលមាននរណាចិញ្ចឹមហ្វូងសត្វ ហើយមិនពិសាទឹកដោះរបស់សត្វក្នុងហ្វូងនោះដែរ។....*" ១កូរិន.៩:៧ "

បន្ទាប់មក គាត់បានបន្តទៀត ដោយចង្អុលទៅឯសញ្ញាចាស់ និងបង្ហាញពីរបៀប ដែលពួកសង្ឃ និងលេវីដែលធ្វើការបំរើប្រចជាជននៅក្នុងវិហារ ក៏បានទទួលការឧបត្ថម្ភពីប្រជាជានដែល។ ត្រង់នេះ គាត់សំដៅទៅលើក្រឹត្យវិន័យនៃដង្វាយ១ភាគ១០ជាប្រពន្ធ័លេវី។ បន្ទាប់មក គាត់បាននិយាយពីការអនុវត្តគោលការណ៍នៃដង្វាយ១ភាគ១០ នៅក្នុង១កូរិន.៩:១៤ "*...រីឯព្រះអម្ចាស់វិញ ព្រះអង្គបានបង្គាប់មកថា អស់អ្នកដែលផ្សព្វផ្សាយដំណឹងល្អ ត្រូវតែចិញ្ចឹមជីវិតដោយសារដំណឹងល្អនោះ។ (ដែលមានប្រពន្ធ័ និងគោលការណ៍)...*

ការសន្និដ្ឋាន បានច្បាស់លាស់ហើយត្រង់នេះ ។ គោលការណ៍នៃការដង្វាយ១ភាគក្នុង១០ដដែលនេះ ដែលនៅក្នុងសញ្ញាចាស់ ត្រូវយកមកអនុវត្តនៅសញ្ញាថ្មីដែរ។ ប៉ូលបាន បញ្ជាក់ថា " ព្រះអម្ចាស់បានតាំងឡើង " យ៉ាងដូច្នេះ តាមប្រមើលទៅ យោងតាមគម្ពីរ ម៉ាថាយ១០:១០ និងលូកា១០:៧-៨ ព្រហយេស៊ូបានមានបន្ទូលប្រាប់សាវករបស់ទ្រង់ ឲ្យទទួលអំណាច និងជំនួយពីពួកអ្នក ដែលពួកសាវកបានធ្វើពន្ធ័កិច្ច ( ផ្សាយព្រះបន្ទូល ) ។ ជាក់ស្តែងផែនការទី១ ត្រូវរួមបញ្ចូលទាំងគោលការណ៍នៃដង្វាយ១ភាគក្នុង១០ដែលជាផ្នែកសំខាន់១នៃសេដ្ឋកិច្ចនៅក្នុងសញ្ញាចាស់ ។

## ថ្ងៃទី១នៃសប្តាហ៍

ប៉ូលក៏បានបញ្ជាក់ផងដែរពីប្រធានបទនៃ ការថ្វាយដង្វាយនៅក្នុង១កូរិន គាត់បានឲ្យដំបូន្មានដដែល ដែលគាត់បានឲ្យ ដល់ពួកជំនុំដដែលនៅក្នុងតំបន់នោះ។

" *រីឯការរៃប្រាក់ ផ្ញើទៅជូនបងប្អូននៅយេរូសាឡឹមវិញ សូមបងប្អូនចាត់ចែងដូចខ្ញុំបានផ្តែផ្តាំដល់ក្រុមជំនុំនានា នៅស្រុកកាឡាទីដែរ គឺរាល់ថ្ងៃអាទិត្យ សូមបងប្អូនយកប្រាក់ទុកដោយឡែកនៅផ្ទះអោយហើយ តាមតែម្នាក់ៗអាចសន្សំបានមិនបាច់ចាំខ្ញុំមកដល់ ទើបនាំគ្នារៃប្រាក់នោះឡើយ*"។ (១កូរិន. ១៦: ១-២)

ព្រះយេស៊ូទតឃើញពួកអ្នកមានយកប្រាក់មកដាក់ក្នុងហិប ថ្វាយព្រះជាម្ចាស់។ ព្រះអង្គទតឃើញស្ត្រីមេម៉ាយក្រីក្រម្នាក់យកប្រាក់ពីរសេន មកដាក់ក្នុងហិបនោះដែរ។ ព្រះអង្គមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះបានដាក់ប្រាក់ច្រើនជាងគេទាំងអស់

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

ដ្បិតអ្នកទាំងនោះបានយកប្រាក់សំណល់របស់ខ្លួនមកដាក់ក្នុងហិប។ រីឯស្ត្រីមេម៉ាយនេះវិញ ទោះបីនាងក្រីក្រយ៉ាងណាក៏ដោយ ក៏នាងយកប្រាក់ទាំងអស់ ដែលនាងត្រូវការជាចាំបាច់សំរាប់ចិញ្ចឹមជីវិត មកដាក់ក្នុងហិប ថ្វាយព្រះជាម្ចាស់ដែរ»។ លូកា២១:១-៤

ត្រង់នេះ គឺជាកម្មវិធីនៃការថ្វាយដង្វាយ ដែលត្រូវមានការបរិច្ចាកយ៉ាងទៀងទៀតប្រចាំសប្តាហ៍ តាមសមមាត្រ ចំពោះអ្នកដែលមានលទ្ធភាពថ្វាយ " តាមដែលព្រះបានចំរើនដល់គាត់ " ។ ការសំដៅយ៉ាងច្បាស់ទៅលើការថ្វាយដង្វាយ១ភាគក្នុង១០ ប្រហែលលើសពី១ភាគ១០ទៅទៀត ។ នៅពេលដែលយើងមើលគម្ពីរកិច្ចការ ២:៤៤-៤៥ និងកិច្ចការ ៤:៣៤-៣៧ ហើយមលកឃើញពីរបៀបដែលពួកគ្រីស្ទានដំបូងបានលក់ទ្រព្យសម្បិត្តរបស់គេនិងបានបែងចែកលុយលក់បាន ដល់គ្រប់គ្នាយើងគួរតែដឹងថា ប៉ូលបានចាត់ចែងឲ្យមានចំនួនអប្បបរមាតិចតួច គឺ១០ភាគរយនៅក្នុងកម្មវិធីថ្វាយដង្វាយ១ភាគក្នុង១០។ នៅក្នុង២កូរិន.៨:១៤ ប៉ុលបានពង្រឹងតំរូវការថ្វាយយ៉ាងទៀងទាត់តាមសមាមារត នៅពេលដេលគាត់បាននិយាយពី " ភាពស្មើគ្នា " ដែលនឹងមិនធ្វើអោយមានបន្ទុកទៅនៃការថ្វាយផ្សេងទៀតយ៉ាងធ្ងន់ធ្ងរទៅលើនរណាម្នាក់ ជាម្នាក់ទៀត។ ការនេះអាចសំរេចទៅបាន ដោយការថ្វាយដង្វាយ១ភាគ១០ប៉ុណ្ណោះ។ គ្រីស្ទានបានទទួលការដាស់តឿនឲ្យថ្វាយដោយទៀងទាត់ ជាប្រពន្ធ័ តាមសមាមាត្រ ដោយសេរី និងជាយញ្ញបូជាផងដែរ។ ប៉ូល បានហៅបែបបទនៃការថ្វាយនេះជា "ព្រះគុណ" ដែលមានគុណធម៍ (គុណសម្បត្តិ) ដដែលដូចព្រះគុណផ្សេងៗទៀតរបស់ពួកគ្រីស្ទ ដូចជា ជំនឿ ពាក្យសំដី ចំណេះដឹង ការអំណត់ និងសេចក្តីស្រលាញ់ (មើល២កូរិន.៨:៧)។ គាត់បានចង្អុលទៅព្រះគ្រីស្ទ ដែលស្ម័គ្រចិត្តថ្វាយអស់ទាំងទ្រព្យសម្បត្តិខាងឋានសួគ៍របស់ទ្រង់ ដែលយើងអាចក្លាយជាអ្នកមាន តាមរយះភាពក្រីក្ររបស់ទ្រង់។ គាត់បានប្រាប់ពីសេរីភាពរបស់ពួកជំនុំនៅក្នុងស្រុកម៉ាសេដូន ហើយជំរុញអោយពួកកូរិនថូស ដើរតាមគំរូដ៏ល្អរបស់ពួកគេ ហើយធ្វើជាគំរូល្អដល់អ្នកឯទៀត គាត់បានប្រាប់ពួកគេថា គាត់បានអួតពីសេរីភាព ហើយសូមកុំឲ្យពួកគេ *"ធ្វើឲ្យគាត់ស្រងាកចិត្ត"*។

ក្រៅពីការថ្វាយដង្វាយ១ភាគក្នុង១០ ជាភារះគ្រឹះរបស់គ្រីស្ទាន ពួកគ្រីស្ទានគួរតែថ្វាយដង្វាយស្ម័គ្រពីចិត្តដែរ ជាផ្នែកខាងសាច់ឈាម នៃជីវិតរបស់ពួកគេ។

គ្រីស្ទាន គឺជាអ្នកបំរើព្រះ និងគឺ ជាអ្នកទទួលខុសត្រូវលើការថ្វាយអ្វីដែលគាត់មាន ដល់ការងាររបស់ព្រះ។ គម្ពីរកិច្ចការមានគំរូជាច្រើនអំពីពួកអ្នកដែលថ្វាយគ្រប់របស់ ដែលគេមាននិងអំពីពួកជំនុំ ដែលប្រមូលដង្វាយ ដើម្បី

ជួយបងប្អូន ដែលខ្វះខាតរបស់ពួកគេនៅក្នុងទីក្រុងផ្សេងទៀត ។ ប៉ុលបានទទួលដង្វាយដែលគាត់យកតាមខ្លួន ទៅក្រុងយេរូសាឡិម ដើម្បីជួយសង្គ្រោះពួកបរិសុទ្ធនៅទីនោះ។ ដោយសាខេបានផ្លាស់ប្រែជាថ្មី គាត់បានថ្វាយទ្រព្យល្អរបស់គាត់ពាក់កណ្ដាលដល់អ្នកក្រ ។ ព្រះយេស៊ូបានសូមឲ្យអ្នក គ្រប់គ្រងច្បាប់ជាអ្នកមាន លក់អស់ទាំងទ្រព្យសម្បត្តិ ដែលគាត់មាន ហើយយកទៅចែកដល់អ្នកក្រ ដើម្បីឲ្យគាត់បានដើរតាមទ្រង់ ដែលជាព្រះអង្គសង្គ្រោះរបស់គាត់។

តាមរយៈឧទាហរណ៍ទាំងនេះ យើងអាចសន្និដ្ឋានដោយសុវត្ថិភាពថា គោលការណ៍នៃការថ្វាយដង្វាយ១ភាគ១០ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ដោយពួកជំនុំដំបូង។ ទោះជាមិនបាននិយាយយ៉ាងជាក់លាក់នៅក្នុងសំបុត្ររបស់ពួកសាវកក៏ដោយ ក៏យើងអាចជឿថាគោលការណ៍នៃការថ្វាយដង្វាយ១ភាគក្នុង១០នៅក្នុងសម័យសញ្ញាចាស់ ក៏យកមកអនុវត្តតទៅទៀត និងអនុវត្តយ៉ាងទូលំទូលាយដោយពួកជំនុំដំបូង និងបានបង្កើតជាផ្នែកយ៉ាងសំខាន់នៃជីវិតរបស់ពួកគេ។ ជាការពិតយើងមិនគួររំពឹងរកឲ្យឃើញ "*ការថ្វាយដង្វាយ១ភាគក្នុង១០*" ថែង ដូចនៅក្នុងសញ្ញាថ្មី ព្រោះថា អត្រា ដែលគ្រីស្ទានបានថ្វាយ មានកំរិតខ្ពស់ជាងចំនួនអប្បបរមា ដែលបានតំរូវដល់ពួកគេ នៅក្នុងដង្វាយ១ភាគ១០ ។

****************

## ដង្វាយស្មគ្រ័ពីចិត្ត

ព្រះមិនគ្រាន់តែចង់បានដង្វាយ១ភាគ១០ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ចង់បានដង្វាយស្មគ្រ័ពីចិត្តពីយើងផងដែរ ដែលយើងគួតែយកទៅថ្វាយទ្រង់នៅក្រុមជំនុំក្នុងស្រុក។ មានគ្រីស្ទានជាច្រើនជឿថា ពួកគេអាចចែកចាយដង្វាយ១ភាគ១០ និងស្មគ្រ័ពីចិត្តនៅកន្លែងណាក៏បានឲ្យតែពួកគេចង់ថ្វាយ។ អ្នកខ្លះមិនថ្វាយដង្វាយ១ភាគ១០ ឬស្មគ្រ័ពីចិត្តទេ។

តើអ្នកឆ្ងល់ទេថា ហេតុអ្វីបានជាមានគ្រីស្ទានជាច្រើន រងគ្រោះដោយភាពក្រីក្រ និងមិនអាចបំពេញតំរូវរបស់ខ្លួន? អ្នកនិងដឹងពីមូលហេតុជាច្រើននៅទំព័រខាងមុខទៀត។ សូមឲ្យយើងមើលព្រះគម្ពីរបរិសុទ្ធទាំងអស់គ្នាសិន ហើយមើលអ្វី ដែលព្រះមានបន្ទូលអំពីដង្វាយស្មគ្រ័ពីចិត្ត នៅក្នុងសញ្ញាចាស់ និងសញ្ញាថ្មី ។

### ៤- ដង្វាយស្មគ្រ័ពីចិត្ត នៅក្នុងសញ្ញាចាស់

**ការថ្វាយយញ្ញបូជា**

"*ហើយពេលអ្នករាល់គ្នាធ្វើយញ្ញបូជាថ្វាយព្រះអម្ចាស់ ទោះបីជាតង្វាយដុតទាំងមូលក្ដី ឬយញ្ញបូជាលាបំណន់ តង្វាយដោយស្ម័គ្រចិត្ត ឬ*

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

*តង្វាយសំរាប់ពិធីបុណ្យដ៏សំខាន់ៗក្តី នោះត្រូវយកគោ ឬចៀម មកថ្វាយ ដើម្បីអោយមានក្លិនឈ្ងុយជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់។* ជនគណនា ១៥:៣

នេះគឺជាក្រឹត្យវិន័យ សំរាប់ការថ្វាយដង្វាយ ជាសត្វដំបូងថ្វាយដល់ព្រះអម្ចាស់។ ពួកគេមិនត្រូវថ្វាយដល់ទ្រង់ តែផលដំបូង និងពោតក្នុងចំការ១ភាគ១០របស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏ថ្វាយផ្នែកនៃអ្វី ដែលពួកគេមាននៅក្នុងផ្ទះ ឬនៅក្នុងកន្លែងដែលចាំបាច់របស់ពួកគេ។ នៅពេលដែលពួកគេជិតរៀបចំម្ហូបម្ហារដាក់លើតុ ផ្នែកនៃសត្វខ្លះត្រូវថ្វាយដង្វាយលើកចុះឡើងដល់ព្រះ ហើយពួកសង្ឃនិងបានដង្វាយនេះ មកប្រើប្រាស់នៅក្នុងគ្រួសាររបស់ពួកគេ។ ពួកសង្ឃពឹងពាក់លើព្រះទាំងស្រុងសំរាប់អាហារប្រចាំថ្ងៃ។ យើងអាននៅក្នុងម៉ាថាយ ៦:១១ អំពីរបៀប ដែលព្រះយេស៊ូបង្រៀនឲ្យយើងអធិដ្ឋាន "សូមព្រះប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ" គឺមិនមែន *"សូមប្រទានផលដែលយើងខ្ញុំត្រូវការនៅឆ្នាំនេះ ទេ។"*

*"ក្នុងចំណោមប្រជាជនគេសង្កត់សង្កិនគ្នាទៅវិញទៅមកម្នាក់ៗសង្កត់សង្កិនបងប្អូនរបស់ខ្លួន។ក្មេងក្មាងប្រឆាំងនឹងចាស់ៗមនុស្សពាលប្រឆាំងនឹងមនុស្សថ្លៃថ្នូរ។"* (អេសាំ ៣: ៥ខ។) ពួកគេម្នាក់ៗបានថ្វាយដង្វាយស្មគ្រ័ពីចិត្តដល់ព្រះអម្ចាស់។ ក្រឹត្យវិន័យតំរូវមានថ្វាយច្រើន ប៉ុន្តែពួកគេនាំយកមកច្រើនថែមទៀត។ ទោះចាពួកគេមានទ្រព្យសម្បត្តិតិចតួចក៏ដោយ ក៏គេថ្វាយយញ្ញបូចា (ដង្វាយ)ស្មគ្រ័ពីចិត្តដែរ ព្រោះពួកគេមានសេចក្តីឧស្សាហ៍ធំ។ យើងអាចសន្និដ្ឋានប៉ុណ្ណោះថា ពួកគេមានអាហារនៅលើតុរបស់ពួកគេតិច ដើម្បីឲ្យពួកគេអាចផ្គត់ផ្គង់អាហាររបស់ព្រះអោយបានបរិបូរ។ វិញ្ញាណនៃការថ្វាយនេះ កំពុងតែបង្ហាញឲ្យគេឃើញតាមសញ្ញាចាស់ និងសញ្ញាថ្មី។ បទគម្ពីរផ្សេងទៀត ដែលទាក់ទងនិងដង្វាយស្ម័គ្រពិចិត្ត នៅក្នុងសញ្ញាចាស់ គឺ ជនគណនា ២៩: ៣៩. ចោទិយកថា ១២:៦. ២៣:២៣ ២របាក្សត្រ ៣១:១៤. អេសាំ ៧:១៦. ៨:២៨ និងទំនុកដំកើង ១១៩:១០៨ សូមបងប្អូនអានបទគម្ពីរទាំងនេះ ។

## ៥ - ដង្វាយស្មគ្រ័ពិចិត្ត នៅក្នុងសញ្ញាថ្មី

### លើសពីភារកិច្ចទៅទៀត

*"កុំធ្វើបុណ្យទាននៅមុខមនុស្សម្នា ដើម្បីអោយតែគេឃើញនោះឡើយ។ ធ្វើបែបនេះអ្នករាល់គ្នាពុំបានទទួលរង្វាន់អ្វីពីព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ*ទេ។*

*ពេលណាអ្នកធ្វើទានដល់ជនក្រីក្រ កុំស្រែកប្រកាសក្តែងៗដូចពួកមានពុតតែងធ្វើនៅក្នុងសាលាប្រជុំ* ឬនៅតាមដងផ្លូវ ដើម្បីអោយមនុស្សម្នាកោត*

*សរសើរនោះឡើយ។ ខ្ញុំសុំប្រាប់អ្នកកាល់គ្នាអោយដឹងច្បាស់ថា អ្នកទាំងនោះបានទទួលរង្វាន់របស់គេហើយ។*

*រីឯអ្នកវិញ កាលណាដៃស្តាំអ្នកធ្វើទាន មិនបាច់អោយដៃឆ្វេងដឹងឡើយ*

*ដើម្បីអោយទានរបស់អ្នកនៅស្ងាត់កំបាំង ហើយព្រះបិតារបស់អ្នក ទតឃើញអំពើដែល អ្នកធ្វើនៅក្នុងទីស្ងាត់កំបាំង ទ្រង់នឹងប្រទានរង្វាន់មកអ្នកវិញ។" ម៉ាថាយ ៦:១-៤.*

*"ក្នុងចំណោមអ្នកកាល់គ្នា ឧបមាថា នរណាម្នាក់មានអ្នកបំរើទៅភ្ជួរស្រែ ឬឃ្វាលហ្វូងសត្វ។ ពេលអ្នកបំរើនោះវិលត្រឡប់មកពីស្រែវិញ ម្ចាស់មិនដែលនិយាយថា "សូមអញ្ជើញមកពិសាបាយ"ទេ។*

*ផ្ទុយទៅវិញ ម្ចាស់តែងតែនិយាយទៅកាន់អ្នកបំរើថា "ចូររៀបចំបាយទឹកអោយខ្ញុំ រួចទៅផ្លាស់ខោអាវមកបំរើខ្ញុំពេលខ្ញុំបរិភោគ ចាំខ្ញុំបរិភោគរួច សឹមអ្នកបរិភោគតាមក្រោយ។*

*ម្ចាស់មិនដែលអរគុណអ្នកបំរើ ដែលបានធ្វើតាមបង្គាប់ខ្លួននោះឡើយ។*

*រីឯអ្នកកាល់គ្នាវិញក៏ដូច្នោះដែរ កាលណាអ្នកកាល់គ្នាបានបំពេញតាមព្រះបញ្ញារបស់ព្រះជាម្ចាស់សព្វគ្រប់ហើយ ចូរពោលថា "យើងខ្ញុំគ្រាន់តែជាអ្នកបំរើធម្មតាប៉ុណ្ណោះ គឺយើងខ្ញុំបានបំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើ"។លូកា ១៧:៧-១០.*

ដើម្បីឲ្យបានជាអ្នកបំរើ ដែលមានប្រយោជន៍ យើងត្រូវទៅលើស១ម៉ាយទៀត និងអនុវត្តការថ្វាយដង្វាយរបស់គ្រីស្ទាន លើសពីភារកិច្ចទៅទៀត បើយើងមានព្រះវិញ្ញាណនៃព្រះនៅក្នុងយើង ទ្រង់និងដឹកនាំយើង និងតំរង់ទិសដៅរបស់យើងឲ្យចេះថ្វាយដង្វាយ ដែលនិងថ្វាយលើពីភារកិច្ចគ្រឹះទៅទៀត។ អ្នកដែលថ្វាយដោយពិតត្រង់ គឺថ្វាយទាល់តែវាឈឺ។

ឥឡូវនេះ សូមមើលអ្វីដែលពួកជំនុំដំបូងបានថ្វាយ។

*"អស់អ្នកដែលបានជឿលើព្រះអម្ចាស់ មានចិត្តគំនិតតែមួយ ហើយយករបស់របរដែលខ្លួនមាន មកដាក់រួមគ្នាទាំងអស់។*

*គេលក់ទ្រព្យសម្បត្តិនិងអ្វីៗជារបស់ខ្លួនយកប្រាក់មកចែកគ្នាតាមសេចក្តីត្រូវការរបស់ពួកគេម្នាក់ៗ។*

*ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ* ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរផង។*

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

*គេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូលគោរពរាប់អានពួកគេទាំងអស់គ្នា។ ព្រះអម្ចាស់បន្ថែមចំនួនអ្នកដែល ព្រះអង្គបានសង្គ្រោះ មកក្នុងក្រុមរបស់គេជារៀងរាល់ថ្ងៃ”។* (កិច្ចការ ២:៤៤-៤៧)

ពួកគេបានលក់ទ្រព្យសម្បត្តិ និងទំនេញរបស់ពួកគេ ពីព្រោះពួកគេមានរបស់របររួមគ្នា។ សព្វថ្ងៃនេះ យើងពិបាករកមនុស្សជាច្រើន ដែលមានរបស់ទ្រព្យរួមគ្នាណាស់។

“*កាលពួកគេទូលអង្វរព្រះជាម្ចាស់ដូច្នោះរួចហើយ កន្លែងដែលគេជួបជុំគ្នានោះក៏រញ្ជួយគេបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធទាំងអស់គ្នា ហើយនាំគ្នាថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយចិត្តអង់អាច។អ្នកជឿទាំងអំបាលម៉ានមានចិត្តថ្លើមតែមួយ គ្មានអ្នកណាម្នាក់នឹកគិតថា ទ្រព្យសម្បត្តិដែលខ្លួនមានជារបស់ខ្លួនផ្ទាល់នោះទ្បើយ គឺគេយកមកដាក់ជាសម្បត្តិរួមទាំងអស់។*

*ក្រុមសាវ័ក*បានប្រកបដោយឫទ្ធានុភាពដ៏ខ្លាំងក្លា ហើយនាំគ្នាផ្ដល់សក្ខីភាពអំពីព្រះអម្ចាស់យេស៊ូមានព្រះជន្មរស់ទ្បើងវិញ។ ព្រះជាម្ចាស់ទ្រង់សំដែងព្រះហឫទ័យប្រណីសន្ដោសដ៏លើសលប់ ដល់ពួកគេទាំងអស់គ្នា។*

*ក្នុងចំណោមពួកគេគ្មាននរណាខ្វះខាតអ្វីទ្បើយ។ អស់អ្នកដែលមានដីធ្លី ឬផ្ទះសម្បែងនាំគ្នាលក់ដីធ្លី និងផ្ទះនោះ យកប្រាក់*

*មកជូនក្រុមសាវ័ក។ បន្ទាប់មក អ្នកជឿទាំងអស់គ្នាទទួលចំណែក តាមសេចក្ដីត្រូវការរៀងៗខ្លួន។*

*មានបុរសម្នាក់ ឈ្មោះយ៉ូស្វេ ជាពួកលេវី ស្រុកកំណើតនៅកោះគីប្រុស ក្រុមសាវ័កបានដាក់ឈ្មោះគាត់ថា បារណាបាស ប្រែថា «អ្នកលើកទឹកចិត្តគេ»។*

*គាត់បានលក់ចំការរបស់គាត់ ហើយយកប្រាក់មកជូនក្រុមសាវ័កដែរ។ កិច្ចការ*

កិច្ចការ៣៧កាបាត់បង់(៤:៣១-៣៧)

មនុស្សទាំងនេះមិនបានខ្វះអ្វីទេ។ ប៉ុន្តែមនុស្សសព្វថ្ងៃនេះ ជាញឹកញាប់តែងស្រែកឃំ ហើយសុំទានព្រះ ឲ្យជួយតំរូវការខាងសម្ភារះ និងហិរញ្ញវត្ថុដល់ពួកគេ ព្រោះពួកគេឆាប់ទៅជាល្ងង់ល្ងើ ធ្វើជាមិនដឹងមិនឮពីសេចក្តីសន្យារបស់ព្រះ ដែលទ្រង់និងបើកបង្អួតឋានសួគ៌ហើយចាត់ព្រះពរដ៏បរិបូររបស់ទ្រង់មក បើសិនជាពួកគេបានថ្វាយ***ដង្វាយ១ភាគក្នុង10ដល់ទ្រង់ជាមុន ។***

*"ហេតុនេះ ម្នាក់ៗត្រូវតែចូលប្រាក់តាមតែខ្លួនសំរេចចិត្ត ដោយមិននឹកស្តាយ ឬទើសទាល់ឡើយ ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណាដែលធ្វើអំណោយដោយចិត្តរីករាយ"។* (២កូរិនថូស ៩:៧)

**ការថ្វាយដង្វាយរបស់គ្រីស្ទាន**

ការថ្វាយដង្វាយរបស់គ្រីស្ទាន ត្រូវតែជាអំពើដោយគ្មានការបង្ខំ និងដោយសេរី ដែលដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។ នេះគឺជាគោលការណ៍១នៃការថ្វាយនៅក្នុងសញ្ញាថ្មី *"កាលណាយើងមានឆន្ទៈល្អ យើងនឹងបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ តាមអ្វីៗដែលយើងមាន គឺមិនមែនតាមអ្វីៗដែលយើងគ្មាននោះទេ។ .....* " (២កូរិនថូស ៨:១២)។ ការថ្វាយដង្វាយនេះក៏ជារឿងផ្ទាល់ខ្លួនផងដែរ ហើយមិនគួរផ្សាយឲ្យសាធារណៈជនដឹងទេ *"រីឯអ្នកវិញ កាលណាដៃស្តាំអ្នកធ្វើទាន មិនបាច់អោយដៃឆ្វេងដឹងឡើយ"* (ម៉ាថាយ ៦:៣)

ព្រះគម្ពីរបានបង្ហាញយើងយ៉ាងច្បាស់ថា ដង្វាយ១ភាគ១០ និងស្មគ្រ័ពីចិត្ត ត្រូវតែនាំយកទៅឯដំណាក់របស់ព្រះ និងប្រគល់ឲ្យពួកលេវី (គឺជាអ្នកបំរើព្រះ ដែលព្រះបានហៅឲ្យបង្រៀនព្រះបន្ទូលរបស់ទ្រង់)។ ម្យ៉ាងទៀត យើងគួរតែនាំយកដង្វាយ១ភាគ១០ និង ដង្វាយស្មគ្រ័ពីចិត្តទៅដាក់នៅក្រុមជំនុំជាទីគោរពរបស់យើង ជាកន្លែងដែលយើង ទទួលបានព្រះបន្ទូល នៃព្រះនោះ ។ ទោះបីយ៉ាងណាក៏ដោយ មានបងប្អូនខ្លះអាចអត់មានក្រុមជំនុំផ្ទាល់ខ្លួនទេ។ ឬអ្នកខ្លះអាចនិយាយថា គេមិនចង់ថ្វាយដង្វាយនៅក្រុមជំនុំ ដែលគេចូលរួមទេ ពីព្រោះ គ្រូគង្វាលនោះមិនអធិប្បាយព្រះបន្ទូលនៃព្រះទេ។ យើងសូមសន្មតិថា អ្នកនិយាយត្រឹមត្រូវ ប៉ុន្តែសូមរកឲ្យឃើញមូលហេតុ ដែលអ្នកថ្វាយដង្វាយ១ភាគ១០ នៃពេលវេលានិងថាមពល ដែលមិនបានប្រើប្រាស់សំរាប់ព្រះសិន។ នៅតំបន់ដែលអ្នករស់នៅ មានមនុស្សជាច្រើនដែលមិនជឿថា ព្រះបានចាត់ហោរាពិតរបស់ទ្រង់ ដើម្បីនាំរាស្ត្ររបស់ព្រះត្រឡប់ទៅឯព្រះបន្ទូលដើមរបស់ទ្រព្យវិញទេ។ ពួកគេមិនបានជឿថា នៅថ្ងៃចុងក្រោយនេះ មានពួកជំនុំពិត ដែលកើតពីពួកថ្វាយបង្គំប្រះដោយពិតត្រង់ ដែលជាសមាជិកនៃកូនក្រមុំរបស់ព្រះគ្រីស្ទទេ។ ពួកគេជឿយ៉ាងនេះវិញថា នរណាក៏ដោយឲ្យតែបានអះអាងថាខ្លួនជាគ្រីស្ទានមិនថា ចាមេតូឌីស្ទ លូថេរ៉ាន អង់គ្លីកិន ឃើរីស្មាទិត។ ល។ គឺជាផ្នែកនៃកូនក្រមុំរបស់ព្រះគ្រីស្ទ ហើយនិងបានជួបព្រះគ្រីស្ទ នៅពេលទ្រង់យាងមកឆក់ពួកជំនុំនោះ។ ជាអកុសល សំរាប់ពួកគេ ព្រះគ្រីស្ទនឹងមិនយាងមកវិញ សំរាប់ គ្រីស្ទាន *"ថម. ឌីក ឬហ៊ែរី"* ទេ។ ទ្រង់យាងមកវិញសំរាប់អ្នកនាដែលជារបស់ផងទ្រង់។

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

សូមអានហាកាយ ១:៤-៧ ហើយរៀនមេរៀន នៃបទគម្ពីរនេះចេះ ។ ជាពិសេស ខ៦បានបង្ហាញយើងថា អស់ទាំងកិច្ចប្រឹងប្រែងរបស់យើងនិងទៅជាអសារឥតការ បើសិនជា យើងមិនបានគិតពីជំណាក់ និងការងាររបស់ព្រះពិតតែ១ជាមុនសិននោះ។ មានគ្រីស្ទានខ្លះជឿថា ការដែលយកលុយទៅជួយអ្នកក្រនោះ គឺគេបានគោរពតាមបញ្ញត្តិរបស់ព្រះហើយ គឺដូចជាបានថ្វាយដង្វាយ១ភាគ១០ និងដង្វាយស្មគ្រ័ពីចិត្ត ដាក់ក្នុងឃ្លាំងរបស់ព្រះដែរ។ ផ្ទុយទៅវិញ ការឲ្យលុយទៅអ្នកក្រ គឺជាអំពើថ្លៃថ្នូរ វាមិនបានសំរេចបញ្ញត្តិរបស់ព្រះអំពីការថ្វាយដង្វាយ១ភាគ១០ និងដង្វាយស្មគ្រ័ពិចិត្តទេ។ សូមអាន កាឡាទី ៦:៦ ម្យ៉ាងទៀត បងប្អូនគួរតែឲ្យរបស់បងប្អូនដល់សំណាប់របស់ព្រះ ដែលទោរទន់ទៅរកតំរូវការខាងវិញ្ញាណរបស់បងប្អូន និងចំអែតបងប្អូន ដោយនំម៉ាន៉ាស្រស់ ដែលមកពីស្ថានសួគ៍។

## ព្រះ ឬ សាតាំង

យើងកំពុងតែរស់នៅយុគសម័យទាំងអស់ ហើយវាជាការចាំបាច់ ឲ្យយើងប្រយ័ត្នពីកន្លែង ដែលយើងថ្វាយដង្វាយ១ភាគ១០ និងដង្វាយស្មគ្រ័ពីចិត្ត។ មានចចកពាក់រោមចៀមកើតឡើងជាច្រើន ដែលកំពុងតែក្រហឹមនៅក្នុងចំណោមហ្វូងតូចនៃព្រះ ដើម្បីនឹករក (ដូចជាគ្រូរបស់គេដែរ-គឺសាតាំង) អ្នកណា ដែលពួកវាអាចនឹងត្របាក់លេបបាន។ យើងដឹងដោយសារព្រះបន្ទូលនៃព្រះ យើងមិនអាចបំរើព្រះផង និងសាតាំងផងបានឡើយ យើងត្រូវស្រលាញ់១ ហើយស្អប់១ ឬគោរព១ ហើយមើលងាយ១។ ជាការពិត ដែលយើង មិនអាចយកលុយរបស់យើងតាមខ្លួនបានទេ។ ទោះបីយ៉ាងណាក៏ដោយ យើងអាច *"ផ្ញើវាបន្តទៅមុខទៀត"* ដូចជាពាក្យគេថា ទៅ ដែលមានន័យថាក្នុងព្រះនេត្រនៃព្រះយើងអាចប្រើប្រាស់លុយរបស់យើងបានត្រឹមត្រូវ។

តើអ្នកមិនចូលចិត្ត ឈរនៅចំពោះព្រះ និង រកឃើញថាអ្នកបានយកដង្វាយ១ភាគក្នុង១០និងដង្វាយស្មគ្រ័ពីចិត្តដាក់ក្នុងកាបូបរបស់អ្នកដែលមានប្រហោងធ្លុះធ្លាយទេឬអី។ ជាការពិត អ្នកមិនចង់ឈរនៅចំពោះព្រះ ឲ្យទ្រង់រកឃើញថា អ្នកបានជួយអារក្សបង្កើតគោលលទ្ធិខុសឆ្គង និងទេវវិទ្យារបស់វាជាច្រើន ជំនួសឲ្យការ ដែលអ្នកមានបំណងចង់បំរើព្រះទេ ។
ដូច្នេហ ចូរចងចាំការនេះជានិច្ច- បើអ្នកថ្វាយអំណោយរបស់អ្នក ទៅកន្លែងពិតប្រាកដណា១ ដែលអ្នកបានដឹងតាមបទគម្ពីរថា ព្រះមិនបានប្រើពួកគេទេ នោះគឺសាតាំងកំពុងប្រើប្រាស់ពួកគេវិញ។

ខ្ញុំសូមអង្វរបងប្អូនថាឲ្យជៀសចេញពីបណ្តាសារ ដែលធ្លាក់មកលើពួកអ្នកប្លន់របស់ព្រះហើយ ខ្ញុំចង់ជំរុញឲ្យបងប្អូនថា មិនត្រូវបានព្រះពររបស់ព្រះ

ទំនាយ ដែលបានបើកសំដែង

ដោយការលូង់លើខាងឯ ការអ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះបានប្រទាន មកអ្នកទេ!!ថ្វាយដង្វាយ១ភាគ១០និងដង្វាយស្មគ្រ័ពីចិត្តឡើយ។

## ៦- លទ្ធផល

សូមអាន *"តាំងពីខ្ញុំនៅក្មេងរហូតមកទល់ពេលខ្ញុំចាស់នេះខ្ញុំមិនដែលឃើញព្រះអម្ចាស់បោះបង់ចោលមនុស្សសុចរិតឡើយហើយក៏មិនដែលឃើញកូនចៅរបស់គេសុំទានដែរ។..."* ទំនុកដំកើង ៣៧:២៥.

*"ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖«ចូរនាំយកតង្វាយមួយភាគដប់ទាំងប៉ុន្មានមកដាក់នៅក្នុងឃ្លាំងដើម្បីអោយមានស្បៀងអាហារក្នុងដំណាក់របស់យើង។ចូរធ្វើយ៉ាងនេះ ដើម្បីល្បងលយើងទៅនោះអ្នករាល់គ្នានឹងឃើញថាយើងនឹងបើកផ្ទៃមេឃបង្ហូរព្រះពរដ៏លើសលប់មកលើអ្នករាល់គ្នា"។* ម៉ាឡាគី ៣:១០.

*"កុំសន្សំទ្រព្យសម្បត្តិទុកសំរាប់ខ្លួន នៅលើផែនដីជាកន្លែងដែលមានកណ្ដៀរ និងច្រែះស៊ី ជាកន្លែងដែលមានចោរទម្លាយជញ្ជាំងចូលមកលួចប្លន់នោះអោយសោះ។ ចូរប្រមូលទ្រព្យសម្បត្តិទុកនៅស្ថានបរមសុខ*វិញ ជាស្ថានដែលគ្មានកណ្ដៀរ និងច្រែះស៊ីជាស្ថានដែលគ្មានចោរទម្លាយជញ្ជាំងចូលមកលួចប្លន់ឡើយ ដ្បិតទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ"។* ម៉ាថាយ ៦:១៩-២១.

*"ចូរសុំ នោះព្រះជាម្ចាស់នឹងប្រទានអោយអ្នករាល់គ្នា ចូរស្វែងរក នោះអ្នករាល់គ្នានឹងបានឃើញ ចូរគោះទ្វារ នោះព្រះអង្គនឹងបើកអោយអ្នករាល់គ្នាជាពុំខាន ដ្បិតអ្នកណាសុំ អ្នកនោះតែងតែបានទទួល អ្នកណាស្វែងរក អ្នកនោះតែងតែបានឃើញ ហើយគេតែងតែបើកទ្វារអោយអ្នកដែលគោះ"។*

ម៉ាថាយ ៧:៧-៨.

*"ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ ទ្រង់នឹងប្រទានមកយ៉ាងបរិបូណ៌ហូរហៀរ។ ព្រះជាម្ចាស់នឹងវាល់អោយអ្នក តាមរង្វាល់ដែលអ្នកវាល់អោយអ្នកដទៃ"។*

លូកា ៦:៣៨.

*"ចូរខំស្វែងរកព្រះរាជ្យ*របស់ព្រះជាម្ចាស់វិញ ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង"។*

*"កុំខ្លាចអី ក្រុមដ៏តូចរបស់ខ្ញុំអើយ! ព្រះបិតារបស់អ្នករាល់គ្នា សព្វព្រះហឫទ័យប្រទានព្រះរាជ្យមកអោយអ្នករាល់គ្នាហើយ។ ចូរលក់ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នា យកប្រាក់ចែកជាទានដល់ជនក្រីក្រចុះ។ ចូរប្រមូលទ្រព្យដែលមិនចេះ*

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

*ពុក ជាសម្បត្តិដែលមិនចេះរលាយ ទុកសំរាប់ខ្លួននៅស្ថានបរមសុខ* ជាស្ថានដែលគ្មានចោរប្លន់ ឬកណ្ដៀរស៊ីឡើយ។ ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នានៅកន្លែងណា ចិត្តរបស់អ្នករាល់គ្នាក៏នៅកន្លែងនោះដែរ"។*

លូកា១២:៣១-៣៤.

*ក្នុងគ្រប់កិច្ចការទាំងអស់ខ្ញុំតែងតែប្រាប់អោយបងប្អូនដឹងថា ត្រូវតែធ្វើការនឿយហត់បែបនេះឯង ដើម្បីជួយទំនុកបម្រុងអស់អ្នកដែលក្រខ្សត់ ហើយត្រូវចងចាំព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូថាៈ "បើអោយ នោះនឹងបានសុភមង្គលច្រើនជាងទទួល"។* កិច្ចការ ២០:៣៥.

*អ្នកណាបោកអាវវែងរបស់ខ្លួនបានស្អាត អ្នកនោះមានសុភមង្គលហើយ គេនឹងមានសិទ្ធិបេះផ្លែពីដើមឈើដែលផ្ដល់ជីវិត ព្រមទាំងចូលទៅក្នុងក្រុងតាមទ្វារផង!។* វិវរណៈ ២២:១៤.

*គេទូលថា «រូប និងឈ្មោះព្រះចៅអធិរាជ»។ ព្រះអង្គក៏មានព្រះបន្ទូលទៅគេថា «អ្វីៗដែលជារបស់ព្រះចៅអធិរាជ ចូរថ្វាយទៅព្រះចៅអធិរាជវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅព្រះជាម្ចាស់វិញដែរ»។*

ម៉ាថាយ ២២:២១.

*ព្រះយេស៊ូក៏មានព្រះបន្ទូលទៅគេថា «អ្វីៗដែលជារបស់ព្រះចៅអធិរាជ ចូរថ្វាយទៅព្រះចៅអធិរាជវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅព្រះជាម្ចាស់វិញដែរ»។ គេងឿងឆ្ងល់នឹងព្រះយេស៊ូយ៉ាងខ្លាំង។*

ម៉ាកុស ១២:១៧.

**********

នៅក្នុងហេព្រើរ ៧:១-១១ សាវកប៉ូល បានចេញការស្រដៀងគ្នារវាងលោកម៉ិលគីស្សាដែក ជាសង្ឃជាព្រះដ៏ខ្ពស់បំផុត (ដែលអ័ប្រាហាំបានថ្វាយដង្វាយ១ភាគ១០ដល់ទ្រង់) និងព្របាយេស៊ូគ្រីស្ទ និងបង្ហាញឲ្យឃើញភាពប្រសើរជាងរបស់ពួកគេទាំង១២ លើសង្ឃ (លេវី)ខាងពូជអើរ៉ុន។ ការជជែករបស់សាវកប៉ូល ក្នុងការគាំទ្រនៃភាពប្រសើរជាងរបស់ព្រះគ្រីស្ទ និងបរាជ័យបើសិនជាព្រះគ្រីស្ទមិនត្រូវបានទទួលដង្វាយ១ភាគក្នុង១០ ដូចលោកម៉ិលគីស្សាដែកបានទទួលនោះ។ សូម្បីតែពួកលេវី (ជាអ្នកត្រូវទទួលដង្វាយ១ភាគ ១០ ) បានបង់ដង្វាយ១ភាគ១០នៅក្នុងអ័ប្រាហាំ។ **បើសិនជាអ័ប្រាហាំ ជាគំរូនៃគ្រីស្ទាន បានថ្វាយដង្វាយ១ភាគក្នុង១០ដល់លោកម៉ិលគីស្សាដែក គឺជាគំរូនៃព្រះគ្រីស្ទនោះ តើពួកគ្រីស្ទាន ដែលពួកគេជាកូនលោកអ័ប្រាហាំនោះគួរតែថ្វាយ ( មិនមែនបង់ទេ )ដង្វាយ១ភាគ១០ទៅអ្នកណា?**

ប៉ូលបានដោះស្រាយបញ្ហានេះ នៅក្នុង៥៨។ គាត់បាននិយាយយ៉ាងសាមញ្ញថា ព្រះគ្រីស្ទ *"បានទទួលដង្វាយ១ភាគក្នុង១០ តែនៅទីនោះ មានសេចក្ដីបន្ទាល់ថា ទ្រង់នៅរស់"។* តើនរណាជាពួកស្មរបន្ទាល់ (សាក្សី) ថា ព្រះគ្រីស្ទនៅមានព្រះជន្មរស់? គឺពួកគ្រីស្ទាន! ក្នុងនាមជាស្មរបន្ទាល់ គ្រីស្ទានត្រូវថ្វាយដង្វាយ១ភាគក្នុង១០ ដល់ព្រះយេស៊ូ។ ប៉ូលមិនអាចពន្យល់ឲ្យងាយជានេះទេ !។

*************

មានមនុស្សច្រើនណាស់នៅក្នុងពិភពលោកយើងនេះដែលអាចធ្វើបន្ទាល់ថា ដោយព្រោះគេបានថ្វាយដង្វាយ១ភាគក្នុង១០ និងដង្វាយស្មគ្រ័ពីចិត្តដោយទៀងទាត់ដល់ព្រះ បានជាពួកគេបានទទួលផលជាច្រើនពីទ្រង់វិញ។ នេះគឺជាផ្លូវ ដែលព្រះបានតាំងឡើងសំរាប់ពួកជំនុំដើម្បីឲ្យដំនើរការខាងហិរញ្ញវត្ថុ។

នៅពេលដែលសាវកប៉ូលបានសរសេរ ១កូរិនថូស ៩:១២-១៤ គាត់បានសំដៅលើជនគណនា ១៨:២១-២៨ ដែលដង្វាយ១ភាគក្នុង១០ត្រូវបង់ទៅឲ្យពួកសង្ឃ។ ហើយគឺដោយព្រះបានតាំងការនេះឡើងនោះ គឺដើម្បីពួកអ្នកដែលបំរើការងារព្រះនៅសម័យសញ្ញាចាស់ គួរតែត្រូវបានគាំទ្រដោយដង្វាយ១ភាគ១០ ពួកអ្នកដែលផ្សាយដំនឹងល្អ នៅពេលបច្ចុប្បន្ននេះ ក៏និងត្រូវរស់នៅដូចជាសង្ឃដែរ។ នេះគឺជាព្រះរាជបញ្ញារបស់ព្រះសំរាប់យើងនៅថ្ងៃនេះ។ ហើយយើងបានឃើញជាក់ថា មានគ្រីស្ទានស្មោះត្រង់ជាច្រើនបានរងទុក្ខជាច្រើនខ្វះខាត-ខាងសម្ភារះ ខាងរូបសាច់ និងខាងវិញ្ញាណ-ជាសាមញ្ញ ដោយព្រោះពួកគេមិនបានឬនិងមិន ថ្វាយដង្វាយ១ភាគ១០ នៃចំណូលរបស់ពួកគេទៅតាមប្រពន្ធ័ ដើម្បីបង្ហាញថាពួកគេស្រលាញ់ និង ដឹងគុណដល់ព្រះទេ។ ការប្រកាសរបស់ ព្រះអំពីបញ្ហានេះ គឺ នៅតែដដែលនៅ យុគសម័យទាំងអស់ - បណ្ដាសានឹងធ្លាក់មកលើពួកមកដែលមិនថ្វាយដង្វាយ១ភាគក្នុង១០ និងព្រះពរនឹងធ្លាក់លើពួកអ្នកដែលបានថ្វាយ។ សូមអាន ម៉ាឡាគី ៣:៨-១២ សុភាសិត ៣:៩-១០. ១១-២៤-២៥។

តើយើងនឹង ប៉ុន្មានដងទៀត? ត្បិតពេលវេលានិង មិនឲ្យយើងប្រាប់មនុស្សជាច្រើន បុរសស្ត្រី ក្មេងប្រុស និងក្មេងស្រី ដែលអាចធ្វើបន្ទាល់ផ្ទាល់ៗខ្លួន ជាមួយនិងការធានា ដែលថាការថ្វាយ១ភាគក្នុង១០ និងដង្វាយស្មគ្រ័ពីចិត្ត គឺជាផ្លូវរបស់ព្រះ ។ អាម៉ែន!

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

> អ្នកនិយាយថា អ្នកថ្វាយបញ្ញបូជានិងថ្វាយរបស់ជាច្រើនដល់ព្រះអម្ចាស់។ ប៉ុន្តែខ្ញុំប្រាប់អ្នកវិញថា អ្នកពិតជាមិនបានថ្វាយទេ ទាល់តែអ្នកថ្វាយដង្វាយ១ភាគ១០
> ដល់ព្រះអម្ចាស់សិន ទើបអ្នកបានថ្វាយពិត- មានតែក្រោយពីថ្វាយដង្វាយ១ភាគ១០ប៉ុណ្ណោះ
>
> r.e.gan

**អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះបានប្រទានមកអ្នកទេ**

## ការដកស្រង់ចេញពីព្រះរាជសាររបស់ហោរា

តើការយកដង្វាយ១ភាគក្នុង១០ ទៅដាក់ក្នុងមូល និធិសាងសង់អាគារខុសឬទេ?

នេះជារឿងមិនទៀងបន្តិចហើយ សំរាប់ពួកជំនុំឥឡូវនេះ។ តាមការត្រឹមត្រូវ *យើងត្រូវថ្វាយដង្វាយ១ភាគក្នុង១០ទៅអ្នកបំរើព្រះ ។ ត្រឹមត្រូវហើយ ។*

នៅក្នុងព្រះគម្ពីរ......ពួកគេមានប្រអប់១ ដែលដាក់នៅជិតទ្វារ (នៅក្នុងសញ្ញាចាស់) នៃអាគារ។ ប្រអប់នេះគឺជាមូលនិធិ ដែលប្រជាជនដាក់នៅទីនោះ សំរាប់ជួសជុល និងថែរក្សាអាគារ និងអ្វីផ្សេងៗដូចនោះដែរ ។ គ្រប់ទាំងការចំនាយលើការជួសជុលលើអាគារ ត្រូវដកចេញពីមូលនិធិនោះ ប៉ុន្តែអស់ទាំងដង្វាយ១ភាគក្នុង១០របស់ពួកគេ ត្រូវយកទៅថ្វាយដល់ពួកសង្ឃ ជាគ្រូគង្វាលរបស់ពួកគេ ។ មិនត្រូវយកដង្វាយ១ភាគក្នុង១០ ទៅដាក់កន្លែងនាផ្សេងពីនេះទេ ។

ខ្ញុំស្គាល់មនុស្ស ដែលយក*ដង្វាយ១ភាគ១០របស់ពួកគេ* និងផ្តល់ទៅឲ្យស្ត្រីមេម៉ាយ បើធ្វើអញ្ចឹង គឺខុសហើយ។

បើសិនជាអ្នកមានរបស់អ្វី ចង់ឲ្យស្ត្រីមេម៉ាយ ចូរឲ្យនាងចុះ ប៉ុន្តែកុំឲ្យយកលុយរបស់ព្រះទៅឲ្យនាង ។ ដង្វាយ១ភាគ១០នេះមិនមែនជារបស់អ្នកទេ។ នោះគឺជារបស់ព្រះ ។

ហើយលេវី ជាសង្ឃ (គ្រូគង្វាល) បានរស់នៅដោយសារ*ដង្វាយ១ភាគក្នុង១០នោះ។ បើយើងថ្វាយដង្វាយ១ភាគក្នុង១០* ចូរទៅក្នុងឃ្លាំងនោះ ដោយមានទាំងសេចក្តីសន្យានៃព្រះ ប្រទានពរការនោះ ។ ទ្រង់មានបន្ទូលថា *"អ្នកមិនជឿខ្ញុំ ចូរមកបញ្ជាក់ពីខ្ញុំ ហើយមើលថាតើខ្ញុំនឹងមិនធ្វើការនេះឬទេ"។* ត្រឹមត្រូវហើយ ។

*ការថ្វាយដង្វាយ១ភាគក្នុង១០ ទៅក្នុងវិហារសំរាប់គ្រូគង្វាល* នឹងរបស់អ្វី ផ្សេងទៀតដើម្បីឲ្យបានរស់នៅ បន្ទាប់មកមូលនិធិកសាងអាគារ និងរបស់អ្វី ដូចនោះ គឺជាមូលនិធិដាច់ដោយឡែកពីគ្នា។

(ដកស្រង់ចេញពី សំនួរ និងចំលើយ ១០ តុលា ៦១)

......សមាគមជំនួយស្ត្រីរបស់អ្នក និងអស់ទាំងអ្វី ដែលមិនសមរម្យ ដែលបាន បន្ថែមចូលព្រះវិហារ....ស៊ុបពេលល្ងាច ត្រូវជូនគ្រូអធិប្បាយព្រះបន្ទូល ។ តើ អ្នកបានអស់ទាំងការបែបនេះ មកពីណា នៅក្នុងបទគម្ពីរ ? ដង្វាយ១ភាគ ១០ បង់ឲ្យគ្រូអធិប្បាយ។ គាត់ត្រូវរស់នៅចេញពីដង្វាយ១ភាគ១0របស់ប្រជា ជន។ ដង្វាយ១ភាគ១០ និងស្មគ្រ័ពីចិត្ត ជូនទៅពួកលេវីដែលជាពួកអ្នកបំរើ ព្រះ។ បើសិនជាអ្នកគ្រប់គ្នាចង់ថ្វាយដង្វាយ១ភាគ១០ អ្នកមិនត្រូវថ្វាយស៊ុប ពេលល្ងាចទេ យល់ទេ? អ្នកបានប្រើប្រាស់របស់ផ្សេងទៀត ហើយទុកដង្វាយ ១ភាគ១0ចោល ។ (ដកស្រង់ពី ក្រឹត្យវិន័យជ្រើសរើសពួកជំនុំសំរាប់ព្រះគុណ ១៦មិនា ៦១)

គ្រប់គ្នាគួរតែផ្ទះក្រុមជំនុំ១។ អ្នកគួរតែមានកន្លែង១សំរាប់ថ្វាយបង្គំព្រះ ។ កុំគ្រាន់តែបណ្តែតខ្លួនពីបង្គោល១ទេ ១ ប៉ុន្តែអ្នកត្រូវទៅកន្លែងណា១ ជាវិហារ ហើយអ្នកហៅវាថាជាវិហាររបស់អ្នក ។ អ្នកគួរតែមានកន្លែងណា១ដើម្បីថ្វាយ ដង្វាយ១ភាគ១០ និងជួយគាំទ្រការងារព្រះនៅទីនោះ។

(ព្រះវិញ្ញាណមានបន្ទូលតាមរយៈហោរា. ៨មិនា៦០ ) ។

នៅពេលព្រះបានដាក់ឲ្យ មានលំដាប់លំដោយ ទ្រង់បានមានបន្ទូលថា "អស់ទាំងពួកលេវីដែលអញបានហៅឯងចេញមក ហើយបានតាំងឯងឲ្យធ្វើ ជាពួកសង្ឃ និងអស់ទាំងបងប្អូនរបស់ឯង គឺជាពូជអំបូរទាំង១១នឹងឲ្យដ ង្វាយ១ភាគក្នុង១០ដល់ឯង។ ហើយឯង (អ្នកដទៃទៀត) ពេលដែលឯង ទទួលបានផ្លែប៉ោម ៩ កញ្ចេរ ចូរឲ្យ១ភាគ១០ដល់ពួកលេវី ។

តើព្រះវិញ្ញាណបរិសុទ្ធជាអ្វី ។ ១៦ធ្នូ៥៩ )

គ្រប់គ្រីស្ទានត្រូវមានភារកិច្ចថ្វាយដង្វាយ១ភាគ១០។ ត្រឹមត្រូវ ។

( ដកស្រង់ចេញពីមេរៀន ហេព្រើរ ជំពូក៧១៥ កញ្ញា ៥៧ )

គ្រប់គ្រីស្ទានមានភារកិច្ចថ្វាយដង្វាយ១ភាគ១០ ព្រោះវាគឺជាព្រះរាជបញ្ជា របស់ព្រះអម្ចាស់ ។ ការថ្វាយដង្វាយ១ភាគក្នុង១០ មានសារៈសំខាន់ដល់បទ ពិសោធរបស់គ្រីស្ទាន ។

ខ្ញុំបានឃ្លាន ហើយម្តាយ និងអ្នកផ្សេងទៀត ហើយឪពុករបស់ខ្ញុំ ឈឺ ប៉ុន្តែ យក អ្នកមិនអាចថ្វាយ លើអ្វី ដែលព្រះប្រទានមកអ្នកទេដង្វាយ១ភាគ១០

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

របស់ខ្ញុំ ទៅថ្វាយព្រះជាមុនសិន ។ គ្រប់គ្រីស្ទានត្រូវតែថ្វាយដង្វាយ១ភាគក្នុង ១០។

(ដកស្រង់ពីមេរៀន យល់ច្រលំព្រះ ២៤ កក្កដា ៦១)

សព្វថ្ងៃនេះពួកគេកំពុងតែយកកន្លែងថ្វាយដង្វាយ១ភាគ១០របស់ព្រះទៅធ្វើជាកន្លែងផ្សេងទៀតដោយស៊ុប លក់នំចាក់ដល់ ដប់លៀងខាងក្រៅព្រះ ដើម្បីអង្កៀសលុយ ដើម្បីសងបំណុលផ្សេងៗ ។ បែបនេះនឹងមិនដែលយកកន្លែងថ្វាយដង្វាយ១ភាគ១០ និងដង្វាយស្មគ្រ័ពីចិត្តដ៏អស់កល្បរបស់ព្រះទេ មិនអាចធ្វើអញ្ចឹងទេ ប៉ុន្តែពួកគេកំពុងខំធ្វើការនោះ ។ តើវាជាអ្វី ? វាគឺជាពួកវិញ្ញាណបញ្ឆោត ។

(មេរៀន ពួកវិញ្ញាណបញ្ឆោត២៤កក្កដា៥៥)

តើមនុស្សម្នាក់ គួរថ្វាយដង្វាយ១ភាគក្នុង១០ ទៅបុគ្គលណាម្នាក់បានឬទេ? វាអាស្រ័យទៅលើថា តើបុគ្គលនោះជានរណាប៉ុណ្ណោះ។ (ចំណាំ ដង្វាយ១ភាគក្នុង១០ត្រូវឲ្យទៅពួកអ្នកបំរើព្រះ) ។ នៅក្នុងពេលដែលអ្នកថ្វាយដង្វាយ១ភាគក្នុង១០ វាពិតជាកន្លែងដែលអ្នកជំពាក់ដង្វាយ១ភាគក្នុង១០ ចាកន្លែងដែលអ្នកទទួលអាហារ ។ *"ចូរនាំយកដង្វាយ១ភាគក្នុង១០ទាំងអស់ មកដាក់ក្នុងឃ្លាំងចុះ។ (ត្រឹមត្រូវទេ?) ហើយល្បងលអញឥលូវ បើអញមិនបើកទ្វារស្ថានសួគ៌ ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ នោះហើយជាព្រះបន្ទូលនៃព្រះយេហូវ៉ានៃពួកពលបរិវារ"។ ខ្ញុំប្រកួតនឹងបុរសឬស្ត្រីដែលមិនមែនជាអ្នកថ្វាយដង្វាយ១ភាគក្នុង១០ ឲ្យទទួលការនោះ ។ បាទ លោក! ខ្ញុំជឿលើការថ្វាយដង្វាយ១ភាគក្នុង១០។ វាគឺជាព្រះពរ១ ដែលបញ្ជាក់ថានឹងត្រូវទទួលព្រះពរ១។ អ្នកនិយាយថា "នោះសំរាប់សញ្ញាចាស់ទេ"* ។ការនោះសំរាប់សញ្ញាថ្មីដែរ ។
បាទ លោក!

(សំនួរ នឹងចំលើយ ២៣ សីហា ៦៤ ពេលល្ងាច )។

*"គ្រុកៗ តោះយើងទៅបរិភោគអាហារពេលល្ងាច នៅពេញ១យប់នេះ យើងត្រូវតែប៉ាវគ្រូគង្វាល ។ យើងត្រូវតែមានរបស់អ្វីលក់ ដើម្បីប៉ាវ"* ។ នៅពេលដែលវានាំទៅកន្លែងនោះ វិហារគួរតែបិតទ្វារទៅ ។ ចូរថ្វាយដង្វាយ១ភាគក្នុង១០ ហើយត្រូវជនដល់គ្រូគង្វាល ។

(មេរៀន តន្ត្រីរបស់ព្រះ ៤ សីហា ៦០)

## សេចក្តីសន្និដ្ឋាន

ចាប់តាំងពីបានសិក្សា ព្រះបន្ទូលនៃព្រះ និង ការបង្រៀនរបស់ហោរាវីល្លៀម ប្រាណហាំយើងបានយល់ថា :

ក/ ការថ្វាយដង្វាយ១ភាគក្នុង១០ គឺជាបញ្ញត្តិរបស់ព្រះអម្ចាស់

ខ/ វាមានសារៈសំខាន់ដល់បទពិសោធរបស់គ្រីស្ទាន ។

គ/ គ្រប់គ្រីស្ទានត្រូវមានភារកិច្ច ថ្វាយដង្វាយ១ភាគ១០ ។

ឃ/ ១ភាគ១០នៃចំណូលរបស់កូនចៅអ៊ីស្រាអែល ជូនទៅសង្ឃជាគ្រូគង្វាលរបស់ពួកគេ និងមិនត្រូវថ្វាយទៅអ្នកណាទេ ។ "**តើមិនដឹងទេឬអី ថា ពួកអ្នក ដែលធ្វើការព្រះ គេគេបរិភោគដោយសារព្រះវិហារ ហើយពួកអ្នកដែលបំរើសាសនា ក៏បានចំណែកពីអាសនាដែរ ។ ព្រះអម្ចាស់ទ្រង់ក៏បង្គាប់ ឲ្យពួកអ្នកដែលផ្សាយដំណឹងល្អ បានរស់ដោយសារដំណឹងល្អដែរ**" (១កូរិនថូស ៩: ១៣-១៤ )។

ច/ យើងមិនត្រូវយកដង្វាយ១ភាគក្នុង១០របស់ព្រះទៅជូនមេម៉ាយ ឬអ្នកក្រទេ ។

ឆ/ ការថ្វាយដង្វាយ១ភាគក្នុង១០ គឺជាសេចក្តីបង្រៀននៅសញ្ញាថ្មី ។

ជ/ ព្រះពរនៃព្រះនឹងធ្លាក់មកលើអស់អ្នក ដែលថ្វាយដង្វាយ១ភាគក្នុង ១០ ។

ឈ/ យើងត្រូវតែនាំយកដង្វាយទៅដាក់នៅក្នុងឃ្លាំងរបស់ព្រះ គឺវិហារ ដើម្បីឲ្យអាចមានអាហារខាងវិញ្ញាណ តាមរដូវត្រូវពេល នៅក្រោមពន្ធកិច្ចនោះ

ញ/ ពួកអ្នក ដែលយកអ្វី មកជំនួសដង្វាយ១ភាគ១០ គឺពួកគេនៅក្រោមឥទ្ធិពលនៃពួកវិញ្ញាណបញ្ឆោត ។

ដ/ ពួកអ្នក ដែលមិនព្រមថ្វាយដង្វាយ១ភាគ១០ គឺជាអ្នកប្លន់របស់ព្រះ ។

ឋ/ យើងត្រូវតែដាក់ព្រះជាមុនដំបូង ។ អ្វីដែលជំពាក់ គឺព្រះជាទី១ បន្ទាប់មកគ្រួសាររបស់អ្នក ជាទី២ និងខ្លួនអ្នកចុងក្រោយ ។

ឱ) អ័ប្រាហាំ ជាឪពុកយើង បានថ្វាយដង្វាយ១ភាគក្នុង១០ ។ ក្នុងនាមជាកូនរបស់គាត់ យើងក៏ត្រូវថ្វាយដង្វាយ ក្នុងនាមជាស្មរបន្ទាល់ **ថាព្រះយេស៊ូគ្រីស្ទ មានព្រះជន្មរស់ ។**

..........

## ចូរស្តាប់ ! ចូរស្តាប់ !

.....អ្នកបានញែកខ្លួនរបស់អ្នក ដើម្បីធ្វើជាគ្រីស្ទាន សំដែងចេញជាគ្រីស្ទាន រស់នៅធ្វើជាគ្រីស្ទានដើម្បីគោរពតាមគ្រប់បញ្ញត្តិ ។

( មេរៀនព្រះបន្ទូលព្រះ ត្រាស់ហៅ ឲ្យញែកចេញទាំងស្រុងពីការមិនជឿ ២១ មករា ៦៤ )

**បើសិនជាអ្នកនិយាយថា អ្នកជឿ តែមិនដើរតាមការប្រដៅជំរង់នៃព្រះបន្ទូល នោះមានន័យថា អ្នកមិនបានជឿទេ ។**

(មេរៀន សញ្ញា១ កញ្ញា ៦៣ )។

អ្នកមិនអាចថ្វាយអ្វី លើអ្វី ដែលព្រះប្រទានមកអ្នកទេ

…………

" ចិញ្ចៀន និងគ្រឿងអល្ល័ង្ការ មិនមែនជាអំណោយទេ ប៉ុន្តែ គឺជា ការសូមខន្តី សំរាប់អំណោយវិញ។
អំណោយពិតតែ១ គឺជាផ្នែកនៃអំណោយនោះ។
-អ៊ីម៉ែរសិន

## ជូនចំពោះមិត្តគ្រីស្ទាន

ជារឿយៗ យើងបានទទួលសំបុត្រពីគ្រីស្ទាននៅប្រទេសផ្សេងៗជាច្រើន ដែលស្នើរសុំឲ្យយើង ជួយពួកគេ។ ជាអកុសល ទោះបីយើងចង់ជួយមនុស្សគ្រប់គ្នាក៏ដោយក៏យើងពិតជាពុំអាចមានលទ្ធភាពផ្តល់ជំនួយដល់ពួកគេដែរ។

មូលហេតុដែលយើងខ្ញុំសរសេរសំបុត្រនេះគឺយើងចង់ឲ្យបងប្អូនបានដឹងពីពន្ធ័កិច្ច PROPHETIC*REVELATION និងសមត្ថភាពខាងហិរញ្ញវត្ថុរបស់យើង។ មានមនុស្សជាច្រើនបាន សរសេរមកយើងថា យើងមានកាតព្វកិច្ចជួយពួកគេ ពីព្រោះពួកគេជាគ្រីស្ទាន។ ពួកគេជាច្រើន មានជំនឿខុស ដោយថា PROPHETIC*REVELATION គឺជាក្រុមជំនុំធំ ឬជាអង្គការធំ ដូច្នេះហើយ គេថា យើងអាចជួយបំពេញតំរូវការរបស់ពួកអ្នកដែលបានសរសេរ មកសុំជំនួយខាងហិរញ្ញវត្ថុពីយើងខ្ញុំបាន។ មិនតែប៉ុណ្ណោះ គេថា ដោយប្រទេសសិង្ហបូរី គឺជាប្រទេស ដែលល្បីល្បាយទូរទាំងពិភពលោក ជាប្រទេសអ្នកមានហើយ បានជាពួកគេចង់សន្និដ្ឋានថា ជនជាតិសិង្ហបូរីទាំងអស់សុទ្ធតែជាអ្នកមាន។

PROPHETIC*REVELATION មិនមែនជាព្រះវិហារ ឬ សង្គមសាសនា ឬអង្គការទេ។ វាក៏មិនបានទទួលការគាំទ្រពីក្រុមសាសនានៅក្នុងស្រុក ឬក្រៅប្រទេសដែរ។ ទោះជាយ៉ាងណាក៏ដោយឥទ្ធិពល និងផលប៉ះពាល់នៃព័ន្ធកិច្ច PROPHETIC*REVELATION នៅក្នុងផ្នែកជាច្រើននៃសកលលោក បាននាំឲ្យគេសន្និដ្ឋានថា PROPHETIC REVELATION ត្រូវតែជាអង្គការធំ ឬ វិហារធំដែលមានសមាជិកច្រើន ។

PROPHETIC*REVELATION គឺជាពន្ធ័១ ដែលព្រះអម្ចាស់យេស៊ូគ្រីស្ទបានដាក់នៅក្នុងចិត្តខ្ញុំក្នុងឆ្នាំ ១៩៧១ ដើម្បីតាំងបទដ្ឋាននៃសេចក្តីពិតក្នុងព្រះគម្ពីរឡើងវិញ ទាល់នឹងខ្មាំងសត្រូវរបស់ទ្រង់ ជាពិសេសនៅក្នុងតំបន់នេះនៃពិភពលោក។ ព្រះបានតាំងឲ្យមាន PROPHETIC*REVELATION នេះ

ទំនាយ ដែលបានបើកសំដែង

ឡើងហើយបានទទួលការគាំទ្រពីសេចក្តីស្រលាញ់ និង វិភាគទានរបស់ពួកអ្នកជឿព្រះរាជសារចុងក្រោយនៅជុំវិញពិភពលោក។ បច្ចុប្បន្ននេះ មិនមានមនុស្សលើសពី ១៧នាក់ទេ ដែលធ្វើការ ជាអ្នកជឿដែលគាំទ្រពន្ធ័កិច្ចនេះយ៉ាងស្មោះត្រង់ដោយពួកគេថ្វាយដង្វាយ១ភាគក្នុង១០ និងស្មគ្រ័ពីចិត្ត យ៉ាងទៀងទាត់ ។ នៅពេលដែលព្រះបានត្រាស់ហៅខ្ញុំ ឲ្យធ្វើពន្ធ័កិច្ចក្នុងឆ្នាំ ១៩៧១ ខ្ញុំចុះកិច្ចព្រមព្រៀង ជាមួយព្រះអម្ចាស់ថា ខ្ញុំនិងធ្វើការនេះឲ្យបានល្អបំផុតដើម្បីសំរេចតាមការត្រាស់ហៅរបស់ទ្រង់ ដរាបណា ខ្ញុំមានអ្នកជឿស្មោះត្រង់នៃព្រះបន្ទូលនៃព្រះ យ៉ាងហោចណាស់១០នាក់ គាំទ្រពន្ធ័កិច្ចនេះ ។ ខ្ញុំមិនជឿលើការកសាងចក្រភពដូចជាគ្រូអធិប្បាយល្បីៗ បានធ្វើសព្វថ្ងៃនេះទេ ។

ដោយមានអ្នកថ្វាយដង្វាយ១ភាគ១០តិចតួចនេះហើយ តើអ្នក គិតថាយើងអាចទទួលប្រាក់ដង្វាយ ចំនួនប៉ុន្មាន ក្នុង១ខែ? ខ្ញុំសូមប្រាប់បងប្អូនថាប្រាក់ខែជាមធ្យមនៅសិង្ហបូរី គឺ១៥៥៧ ដុល្លារសិង្ហបូរី (ឬប្រហែល ៩៦០ ដុល្លារសហរដ្ឋអាមេរិច) ។ ចូរចងចាំថា នេះគឺជាចំនូលមធ្យម មិនមែនជាចំនូលទាបបំផុតទេ ។

ដង្វាយ ដែលប្រមូលបាន ត្រូវយកទៅចំណាយលើការបោះពុម្ភផ្សាយ ៤ ដងក្នុង១ឆ្នាំ១ដង ៥000ច្បាប់ អំពី PROPHETIC*REVELATION ចំណាយលើការផ្ញើសៀវភៅ និងកាសែតតាមប្រៃសណីយ ចំណាយលើសម្ភារះបោះពុម្ភផ្សេង ចំណាយលើការទិញកាសែត ទិញម៉ាញ៉េថត ក្រដាស និងសម្ភារះការិយាល័យ។ ល ។ ហើយចំនួនលុយដែលនៅសល់ បើសល់ យើងនិងសន្សំទុក សំរាប់ការធ្វើបេសកកម្ម ។

មានពេលជាច្រើនដង ដែលយើងខ្វះមូលនិធិ ដើម្បីបំពេញការចំណាយ ប៉ុន្តែពេលនិ១ៗនោះ ព្រះបានបំពេញតំរូវការយើងទាន់ពេល ។ ទ្រង់មិន ដែលឲ្យយើងខកចិត្តឡើយ ព្រោះយើងចេះតែទុកចិត្តលើទ្រង់។

ដូច្នេះខ្ញុំសូមអធិស្ថានឲ្យអ្នកបានយល់ថា PROPHETIC*REVELATION ពិតជា នៅក្នុង ព្រះហស្តព្រះទាំងស្រុង។ យើងស្រលាញ់ និង ជួយដល់អ្នកដែលត្រូវការជំនួយ ប៉ុន្តែតំរូវការនោះខ្ពស់ជាលទ្ធភាព ដែលយើងមានទៅទៀតមានតែព្រះទេដែលអាចជួយយើងបានទាំងអស់ ។

សូមព្រះប្រទានពរ

ដោយសេចក្តីស្មោះត្រង់

ពីខ្ញុំបាទ រីឆីត ល.ស ហ្កាន់

អ្នកផ្សព្វផ្សាយ

ឆ្នាំ ១៩៩២

សត្វឥន្ទ្រីស្រែក...





...សត្វព្រាបនាំ

**PROPHETIC*REVELATION**
**Ghim Moh Estate Post Office Box 333**
**Republic of Singapore 912742**